

# របាយការណ៍ស្ដីពី បញ្ហាប្រឈម នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

## ឆ្នាំ២០២៥

ccimcambodia.org

គ្រប់គ្នាទទួលបានព័ត៌មានគ្រប់គ្នាទទួលបានភាពអង់អាច

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
CCIM
cambodian center for independent media

## មាតិកា


ខ្លឹមសារសង្ខេប ........ 1
សេចក្តីផ្តើម ........ 4
វិធីសាស្ត្រ ........ 5
ដែនកំណត់ ........ 7
ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ ........ 8
I. ការកើនឡើងនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ និងការពន្យារពេលអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននាំឱ្យមានការរឹតត្បិតដល់ការទទួលបានព័ត៌មានផ្លូវការ ........ 11
II. របកគំហើញទី១៖ បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានឯករាជ្យ ........ 15
១.១. សកម្មភាពនៃការដាក់សម្ពាធ និងការរឹតត្បិតលើការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ........ 15
១.២. ភាគច្រើននៃអ្នកសារព័ត៌មានបានអនុវត្តការដាក់កំហិតខ្លួនឯងក្នុងឆ្នាំ២០២៥ ........ 17
១. ៣. ៩៤%នៃអ្នកសារព័ត៌មានបង្ហាញថាមានការព្រួយបារម្ភអំពីសុវត្ថិភាព ........ 18
១. ៤. អ្នកសារព័ត៌មានភាគច្រើនបានបង្ហាញការព្រួយបារម្ភអំពីហានិភ័យជាប់ពន្ធនាគារ និងវិធានការផ្លូវច្បាប់ផ្សេងៗ ........ 18
១.៥. បទពិសោធន៍បញ្ហាសុវត្ថិភាពដែលជួបប្រទះ ........ 20
១.៦ ទំនាក់ទំនងរវាងអ្នកសារព័ត៌មានជាមួយស្ថាប័នរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ........ 20
III. របកគំហើញទី២៖ ប្រធានបទរសើបនាំឱ្យមានការបារម្ភក្នុងចំណោមអ្នកសារព័ត៌មាន ........ 23
IV. របកគំហើញទី៣៖ ការទទួលបានព័ត៌មាន ........ 24
V. របកគំហើញទី៤៖ ភាពតានតឹងផ្លូវចិត្តពាក់ព័ន្ធនឹងការងារ និងសុខភាពផ្លូវចិត្តរបស់អ្នកសារព័ត៌មាន ........ 26
VI. របកគំហើញទី៥៖ អ្នកសារព័ត៌មានធ្លាប់រងការបៀតបៀនផ្លូវភេទក្នុងពេលបំពេញការងាររបស់ខ្លួនក្នុងនោះមាន ៣៥% ប៉ុណ្ណោះនៃពួកគេបានរាយការណ៍ថាស្ថាប័នសារព័ត៌មានរបស់ខ្លួនមានយន្តការគាំទ្រ ........ 26
VII. របកគំហើញទី៦៖ ការឆ្លើយតបយេនឌ័រ និងសមភាពនៅក្នុងស្ថាប័នសារព័ត៌មាន ........ 27
VIII. របកគំហើញទី៧៖ យន្តការគាំទ្រសម្រាប់អ្នកសារព័ត៌មាន ........ 30
IX. របកគំហើញទី៨៖ ការកើនឡើងនៃព័ត៌មានមិនពិត និងព័ត៌មានបំភាន់ដែលបង្កើតឡើងដោយបញ្ញាសិប្បនិម្មិត ........ 32
V. របកគំហើញទី៩៖ តម្រូវការកសាងជំនាញសម្រាប់អ្នកសារព័ត៌មាននាពេលអនាគត ........ 35
សេចក្តីសន្និដ្ឋាន ........ 37
អនុសាសន៍ ........ 38

## ខ្លឹមសារសង្ខេប

ការសិក្សានេះវាយតម្លៃអំពីទិដ្ឋភាពនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ របាយការណ៍នេះ ផ្អែកលើការដកស្រង់ចេញពីការស្រាវជ្រាវលើឯកសារដែលមានស្រាប់ ការស្ទង់មតិតាមអនឡាញជាមួយអ្នកសារព័ត៌មាន និងពលរដ្ឋអ្នកសារព័ត៌មានចំនួន១០៩នាក់ ការពិភាក្សាជាក្រុមចំនួន៤ក្រុម និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះចំនួន៩ក្រុម។ របាយការណ៍នេះបានរកឃើញថា បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជានៅតែរងសម្ពាធកាន់តែស្មុគស្មាញបើប្រៀបធៀបទៅនឹងឆ្នាំ២០២៤។

«របាយការណ៍ស្តីពីបញ្ហាប្រឈមនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឆ្នាំ២០២៥» បានបង្ហាញថាសេរីភាពសារព័ត៌មាននៅកម្ពុជាបន្តធ្លាក់ចុះ ដោយអ្នកសារព័ត៌មានចំនួន ៦៩% ដែលបានចូលរួមការស្ទង់មតិ បានរាយការណ៍ពីការព្រួយបារម្ភអំពីការចាប់ខ្លួនដែលជាសម្ពាធខ្លាំងបំផុតសម្រាប់ពួកគាត់ (តួលេខទី៣) និង ៣៩% មានការព្រួយបារម្ភអំពីសុវត្ថិភាព (តួលេខទី៤)។

ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ នៅតែជាបញ្ហាប្រឈមដ៏សំខាន់ ហើយក្នុងករណីខ្លះ ត្រូវបានប្រើប្រាស់មកលើអ្នកសារព័ត៌មានដែលបានបង្កើតបរិយាកាសនៃភាពមិនច្បាស់លាស់ផ្នែកច្បាប់ និងការដាក់កំហិតខ្លួនឯង។ ការបន្តប្រើប្រាស់បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលមាននិយមន័យទូលាយជាពិសេស បទញុះញង់ និងបទបរិហារកេរ្តិ៍បានរួមចំណែកបង្កើតបរិយាកាសរឹតត្បិតនេះ។ នៅឆ្នាំ២០២៥ សម្ពាធទាំងនេះបានកើនឡើងបន្ថែមទៀតតាមរយៈការប្រើប្រាស់បទប្បញ្ញត្តិសន្តិសុខជាតិ រួមទាំងមាត្រា ៤៤៥ ដែលមានអ្នកសារព័ត៌មានចំនួនពីរនាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៤ ឆ្នាំ។ បទប្បញ្ញត្តិថ្មីៗដូចជាប្រកាសស្តីពីលក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មានសម្រាប់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ ដែលចេញផ្សាយថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ក៏បានដាក់ចេញនូវលក្ខខណ្ឌតម្រូវការកាន់តែតឹងរ៉ឹងសម្រាប់ការទទួលស្គាល់សារព័ត៌មាន ដែលបានបង្កើនក្តីបារម្ភអំពីឧបសគ្គដល់អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មាន។

ការសិក្សានេះបានរកឃើញរបកគំហើញសំខាន់ៗចំនួន ៩ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការសន្និដ្ឋាន និងអនុសាសន៍អំពីស្ថានភាពសារព័ត៌មាន និងបញ្ហាប្រឈមនានាដែលអ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មានកំពុងប្រឈមមុខនាពេលបច្ចុប្បន្ន។

**របកគំហើញទី១ បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានឯករាជ្យ៖** អ្នកសារព័ត៌មានបានរាយការណ៍អំពីការប្រឈមនឹងសម្ពាធយ៉ាងខ្លាំងទាំងបរិយាកាសខាងក្នុង និងខាងក្រៅ។ ៩៤% នៃអ្នកចូលរួមស្ទង់មតិ (តួលេខទី២) បានបង្ហាញពីក្តីបារម្ភយ៉ាងខ្លាំងអំពីសុវត្ថិភាព ដោយអ្នកចូលរួមស្ទង់មតិជាច្រើនបានរាយការណ៍ពីការភ័យខ្លាចជាបន្តបន្ទាប់ចំពោះការគំរាមកំហែងផ្នែកច្បាប់ រួមទាំងហានិភ័យនៃការជាប់ពន្ធនាគារ ឬចំណាត់ការផ្លូវច្បាប់បន្ទាប់ពីការចុះផ្សាយព័ត៌មាន។ អ្នកសារព័ត៌មានភាគច្រើនបានលើកឡើងថា ប្រភពនៃការគំរាម

កំហែងភាគច្រើនកើតឡើងតាមរយៈមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋានគឺជាអ្នកប្រព្រឹត្តការបៀតបៀន និងការបំភិតបំភ័យ។

**របកគំហើញទី២ ប្រធានបទរសើបនាំឱ្យមានការបារម្ភក្នុងចំណោមអ្នកសារព័ត៌មាន៖** ការរាយការណ៍ព័ត៌មានអំពីប្រធានបទរសើប ជាពិសេសអំពើពុករលួយ និងការរុករកធនធានធម្មជាតិដោយខុសច្បាប់ ការកាប់បំផ្លាញព្រៃឈើ និងការបំផ្លិចបំផ្លាញព្រៃឈើ ត្រូវបានរកឃើញថា បង្កឱ្យមានក្តីបារម្ភកាន់តែខ្ពស់ក្នុងចំណោមអ្នកសារព័ត៌មាន។ ការរាយការណ៍លើប្រធានបទទាំងនេះ ត្រូវបានភ្ជាប់ជាញឹកញាប់ជាមួយនឹងការប្រឈមនឹងការគំរាមកំហែង និងចំណាត់ការតាមផ្លូវច្បាប់ដែលធ្វើឱ្យក្លាយជាការងារដែលមានហានិភ័យខ្ពស់បំផុតសម្រាប់អ្នកសារព័ត៌មានដូចដែលបានកត់ត្រានៅក្នុងការសិក្សានេះ។

**របកគំហើញទី៣ ការទទួលបានព័ត៌មាន៖** ការទទួលបានព័ត៌មាននៅតែជាឧបសគ្គដ៏សំខាន់សម្រាប់អ្នកសារព័ត៌មាន បញ្ហាប្រឈមដែលត្រូវបានរាយការណ៍ញឹកញាប់បំផុត គឺការលំបាកក្នុងការស្នើសុំទិន្នន័យ ឬការទទួលបានឱកាសសម្ភាសន៍ជាមួយមន្ត្រីរដ្ឋាភិបាល។ គួរកត់សម្គាល់ថា សូម្បីតែការបង្ហាញបណ្ណសារព័ត៌មានដែលមានសុពលភាព ឬអត្តសញ្ញាណផ្លូវការពីស្ថាប័ន ក៏មិនអាចធានាថាទទួលបានព័ត៌មាននោះទេ ដោយអ្នកសារព័ត៌មានជាច្រើនបានរាយការណ៍ថា ឯកសារទាំងនេះមិនគ្រប់គ្រាន់ដើម្បីទទួលបានការសម្ភាស ឬទាញយកព័ត៌មានពីប្រភពសំខាន់ៗឡើយ។

**របកគំហើញទី៤ ភាពតានតឹងផ្លូវចិត្តពាក់ព័ន្ធនឹងការងារ និងសុខភាពផ្លូវចិត្តរបស់អ្នកសារព័ត៌មាន៖** របកគំហើញបង្ហាញពីតម្រូវការបន្ទាន់សម្រាប់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្តដល់អ្នកសារព័ត៌មាន។ បញ្ហាកង្វះខាតផ្នែកហិរញ្ញវត្ថុ និងការព្រួយបារម្ភជាបន្តបន្ទាប់អំពីសុវត្ថិភាពផ្ទាល់ខ្លួនត្រូវបានកំណត់ថាជាមូលហេតុចម្បងដែលបង្កឱ្យមានភាពតានតឹងផ្លូវចិត្ត ដោយអ្នកចូលរួមក្នុងការស្ទង់មតិចំនួន ៣០% បានរាយការណ៍ថាពួកគាត់បានស្វែងរកការប្រឹក្សា ការព្យាបាល ឬសេវាគាំទ្រផ្នែកសុខភាពផ្លូវចិត្ត។

**របកគំហើញទី៥ អ្នកសារព័ត៌មានធ្លាប់រងការបៀតបៀនផ្លូវភេទក្នុងអំឡុងពេលបំពេញការងាររបស់ខ្លួន ក្នុងនោះមាន៣៥% នៃពួកគេបានរាយការណ៍ថាស្ថាប័នសារព័ត៌មានរបស់ខ្លួនមានយន្តការគាំទ្រ៖** អ្នកសារព័ត៌មានបានជួបប្រទះការបៀតបៀនផ្លូវភេទក្នុងពេលបំពេញការងារ។ របកគំហើញបានបង្ហាញពីតម្រូវការបន្ទាន់សម្រាប់ស្ថាប័នសារព័ត៌មានក្នុងការបង្កើតយន្តការច្បាស់លាស់ និងអាចអនុវត្តបានដើម្បីដោះស្រាយបញ្ហាការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។ បច្ចុប្បន្ននេះមានតែអ្នកសារព័ត៌មានចំនួន ៣៥% ប៉ុណ្ណោះក្នុងចំណោមអ្នកចូលរួមស្ទង់មតិដែលបានរាយការណ៍ថា ស្ថាប័នសារព័ត៌មានរបស់ពួកគាត់មានយន្តការផ្លូវការសម្រាប់ដោះស្រាយបញ្ហាប្រភេទនេះ ដែលចំនួននេះក៏បង្ហាញពីកង្វះយន្តការការពារពីស្ថាប័នសារព័ត៌មានផងដែរ។

**របកគំហើញទី៦ ការឆ្លើយតបយេនឌ័រ និងសមភាពនៅក្នុងស្ថាប័នសារព័ត៌មាន៖** របកគំហើញបង្ហាញពីគម្លាតដ៏គួរឱ្យកត់សម្គាល់ ក្នុងវិធីសាស្ត្រដែលស្ថាប័នសារព័ត៌មានជ្រើសរើស គាំទ្រ និងលើកកម្ពស់

ស្ត្រី និងភាពចម្រុះផ្នែកយេនឌ័ររបស់អ្នកជំនាញនៅក្នុងវិស័យសារព័ត៌មាន។ ភស្តុតាងដែលទទួលបានពីការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះក៏បានបង្ហាញបន្ថែមថា អ្នកសារព័ត៌មានស្ត្រីប្រឈមនឹងបញ្ហាដ៏ស្មុគស្មាញហើយក៏មានបញ្ហាទាំងផ្នែករចនាសម្ព័ន្ធ វិជ្ជាជីវៈ និងយេនឌ័រ ដែលបានកម្រិតយ៉ាងខ្លាំងដល់ការទទួលបានឱកាសសំខាន់ៗក្នុងអាជីព និងតួនាទីជាអ្នកដឹកនាំ។

**របកគំហើញទី៧ យន្តការគាំទ្រសម្រាប់អ្នកសារព័ត៌មាន៖** តាមរយៈលទ្ធផលសិក្សាបានបង្ហាញថា ស្តង់ដារផ្នែកនិពន្ធ និងសុវត្ថិភាពក្នុងការរាយការណ៍ព័ត៌មាន នៅតែជាផ្នែកសំខាន់ដែលស្ថាប័នសារព័ត៌មានត្រូវផ្តោតការយកចិត្តទុកដាក់ជាចម្បង។ ទោះជាយ៉ាងណា យន្តការគាំទ្រសំខាន់ៗផ្សេងទៀតរួមមាន ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត គោលនយោបាយប្រឆាំងការរើសអើង និងការបៀតបៀនផ្លូវភេទ គោលនយោបាយឆ្លើយតបនឹងសមភាពយេនឌ័រ និងការអនុវត្តផ្តល់ប្រាក់កម្រៃស្មើភាពនៅតែជាអាទិភាព ដែលមិនទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ។ គួរកត់សម្គាល់ថា តិចជាងពាក់កណ្តាលនៃអ្នកចូលរួមស្ទង់មតិបានរាយការណ៍ថាស្ថាប័នសារព័ត៌មានរបស់ពួកគាត់មានស្តង់ដារទាំងនេះជាផ្លូវការ ប៉ុន្តែវានៅតែបង្ហាញពីគម្លាតដ៏ធំរវាងតម្រូវការជាក់ស្តែង និងអ្វីដែលត្រូវអនុវត្តបន្ថែមទៀតនាពេលបច្ចុប្បន្ន (តួលេខទី៩)។

**របកគំហើញទី៨ ការកើនឡើងនៃព័ត៌មានមិនពិត និងព័ត៌មានបំភាន់ដែលបង្កើតដោយបញ្ញាសិប្បនិម្មិត AI៖** តាមរយៈលទ្ធផលសិក្សាបានបង្ហាញពីគម្លាតដ៏សំខាន់មួយនៃសមត្ថភាពបច្ចេកទេសនៅក្នុងវិស័យសារព័ត៌មាន ជាពិសេសលើសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការផ្ទៀងផ្ទាត់មាតិកាដែលបង្កើត ឬកែប្រែដោយបញ្ញាសិប្បនិម្មិត។ ក្នុងនោះអ្នកចូលរួមស្ទង់មតិចំនួន ៧៤% បានបញ្ជាក់ថា ការបណ្តុះបណ្តាលអំពីមាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិតគឺជាតម្រូវការដ៏បន្ទាន់។ ទន្ទឹមនឹងនេះក៏មានតម្រូវការក្នុងការបង្កើតគោលការណ៍ណែនាំដែលមានតម្លាភាព និងអាចអនុវត្តបានសម្រាប់គ្រប់គ្រងការប្រើប្រាស់បញ្ញាសិប្បនិម្មិតនៅក្នុងស្ថាប័នសារព័ត៌មាន។ របកគំហើញទាំងនេះបានបញ្ជាក់ថា វិស័យសារព័ត៌មានត្រូវតែចាត់ទុកចំណេះដឹងអំពីបញ្ញាសិប្បនិម្មិត មិនមែនត្រឹមតែជាជំនាញបន្ទាប់បន្សំនោះទេ ប៉ុន្តែជាសមត្ថភាពវិជ្ជាជីវៈមូលដ្ឋាន និងបន្ទាន់មួយដែលតម្រូវឱ្យមានការវិនិយោគរួមគ្នាទាំងផ្នែកបណ្តុះបណ្តាល និងគោលនយោបាយស្ថាប័ន ដើម្បីធានាឱ្យមានការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយទំនួលខុសត្រូវ ការយល់ដឹងច្បាស់លាស់ និងក្រមសីលធម៌ក្នុងវិស័យសារព័ត៌មាន។

**ជាចុងក្រោយ របកគំហើញទី៩ តម្រូវការកសាងជំនាញសម្រាប់អ្នកសារព័ត៌មាននាពេលអនាគត៖** លទ្ធផលការសិក្សាបានបង្ហាញពីទិសដៅនាពេលអនាគត ដោយកំណត់អំពីការវិនិយោគលើការកសាងសមត្ថភាព និងអាទិភាពនៃការអភិវឌ្ឍជំនាញដែលចាំបាច់សម្រាប់ការត្រៀមខ្លួនរបស់អ្នកជំនាញសារព័ត៌មានក្នុងការឆ្លើយតបទៅនឹងឧស្សាហកម្មដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ អ្វីដែលសំខាន់នោះ គឺតម្រូវការនេះមិនត្រឹមតែគ្របដណ្តប់លើអ្នកសារព័ត៌មានបម្រើការងារពេញម៉ោងប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងអ្នកសារព័ត៌មានសេរី (Freelancers) និងពលរដ្ឋអ្នកសារព័ត៌មាន (CJs) ផងដែរដែលជាក្រុមកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងបរិបទប្រព័ន្ធផ្សព្វផ្សាយសម័យទំនើប ហើយជាញឹកញាប់ពួកគេមិនទទួលបានឱកាសបណ្តុះបណ្តាលផ្លូវការ។

## សេចក្តីផ្តើម

នៅឆ្នាំ២០២៥ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា បានដំណើរការក្នុងបរិយាកាសដ៏ស្មុគស្មាញ និងកាន់តែមានការរឹតត្បិតដែលត្រូវរងសម្ពាធជាច្រើនរួមមាន ផ្នែកច្បាប់ នយោបាយ ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា។ នៅក្នុងឆ្នាំ២០២៥ នេះមានការវិវត្តសំខាន់ៗមួយចំនួនរួមមាន ការកាត់បន្ថយថវិកាជំនួយអន្តរជាតិធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នព័ត៌មាន ការកើនឡើងនៃភាពរសើបជុំវិញការរាយការណ៍ព័ត៌មានអំឡុងពេលភាពតានតឹងតាមព្រំដែនកម្ពុជា-ថៃ និងការដាក់ឱ្យអនុវត្តវិធានការបទប្បញ្ញត្តិថ្មីៗ សម្រាប់គ្រប់គ្រងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។ លើសពីនេះ ក៏មានការការរីកចម្រើនយ៉ាងឆាប់រហ័សនៃទម្រង់ឌីជីថល និងបញ្ញាសិប្បនិម្មិតបានធ្វើឱ្យមានការរីករាលដាលនៃព័ត៌មានមិនពិត និងព័ត៌មានបំភាន់ ព្រមទាំងបានផ្លាស់ប្តូររបៀបដែលទស្សនិកជនទទួលបាន និងចូលរួមជាមួយព័ត៌មាន។

ក្នុងបរិបទនេះ អ្នកសារព័ត៌មានកំពុងប្រឈមមុខនឹងបញ្ហាកាន់តែច្រើនក្នុងការផលិតព័ត៌មាន ដែលបម្រើផលប្រយោជន៍សាធារណៈ។ បញ្ហាទាំងនេះរួមមាន ការកើនឡើងនៃហានិភ័យផ្នែកច្បាប់ អស្ថិរភាពហិរញ្ញវត្ថុ ការរឹតត្បិតលើការទទួលបានព័ត៌មាន និងការគំរាមកំហែងថ្មីៗក្នុងបរិបទឌីជីថល ដូចជាព័ត៌មានមិនពិត និងព័ត៌មានបំភាន់ ដែលជំរុញដោយបញ្ញាសិប្បនិម្មិត។ សម្ពាធទាំងនេះបានប៉ះពាល់ដល់សមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការរាយការណ៍ព័ត៌មានដោយសេរី និងមានសុវត្ថិភាព ស្របពេលបានរួមចំណែកធ្វើឱ្យការអនុវត្តនៅក្នុងស្ថាប័នសារព័ត៌មានកាន់តែមានការប្រុងប្រយ័ត្នខ្ពស់ នាំឱ្យមានផលប៉ះពាល់កាន់តែខ្លាំងទៅលើភាពត្រឹមត្រូវនៃព័ត៌មាន និងទំនុកចិត្តរបស់សាធារណជន។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយកឯករាជ្យ ហៅកាត់ថា «ម.ក.ប.រ» បានចេញផ្សាយរបាយការណ៍ស្តីពី «បញ្ហាប្រឈមនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ» ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៣មក។[1] របាយការណ៍នេះបានផ្តល់នូវការវាយតម្លៃជាប្រចាំអំពីបរិយាកាសនៃការអនុវត្តវិជ្ជាជីវៈសម្រាប់អ្នកសារព័ត៌មានឯករាជ្យនៅកម្ពុជា។ ព្រមទាំងកត់ត្រាអំពីការវិវត្តសំខាន់ៗក្នុងវិស័យសារព័ត៌មាន រួមមានការផ្លាស់ប្តូរផ្នែកច្បាប់ និងបទប្បញ្ញត្តិ សម្ពាធនយោបាយ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងហានិភ័យផ្នែកសុវត្ថិភាពដែលអ្នកសារព័ត៌មានបានប្រឈមរួមទាំងផ្តល់សំណើ និងអនុសាសន៍ដល់ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មានដើម្បីឆ្លើយតបនឹងការប្រឈម។

របាយការណ៍នេះមានគោលបំណងផ្តល់ជាធនធានដែលផ្អែកលើមូលដ្ឋានជាក់ស្តែង និងភស្តុតាងសម្រាប់អ្នករៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អ្នកអនុវត្តការងារផ្នែកសារព័ត៌មាន និងដៃគូអន្តរជាតិ។ ជាងនេះទៅទៀត ក៏គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងសេរីភាពសារព័ត៌មាន និងភាពធន់របស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ជាពិសេសក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរនានា ដែលកំពុងកំណត់ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយនៅឆ្នាំ២០២៥។

---

[1] «របាយការណ៍ស្តីពី បញ្ហាប្រឈមប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឆ្នាំ២០២៤ (ភាសាអង់គ្លេស)» ម.ក.ប.រ ឆ្នាំ២០២៤, https://ccimcambodia.org/?page_id=6232 ។

## វិធីសាស្ត្រ

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវចម្រុះ ដោយរួមបញ្ចូលវិធីសាស្ត្រប្រមូលទិន្នន័យបែបបរិមាណ និងគុណភាពដើម្បីផ្តល់នូវការយល់ដឹងដ៏ច្បាស់លាស់អំពីបញ្ហាប្រឈម ដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកំពុងជួបប្រទះ។ ការប្រមូលទិន្នន័យត្រូវបានអនុវត្តតាមរយៈការស្រាវជ្រាវលើឯកសារដែលមានស្រាប់ ការស្ទង់មតិតាមអនឡាញ កិច្ចពិភាក្សាក្រុម និងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះដែលការប្រមូលទិន្នន័យនេះបានចាប់ផ្តើមពីខែមករា ដល់ដើមខែកុម្ភៈ ឆ្នាំ២០២៦។



**ការស្រាវជ្រាវលើឯកសារដែលមានស្រាប់៖** ដំណើរការសិក្សាបានវិភាគអំពីទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្នតាមរយៈអត្ថបទព័ត៌មាន សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មាន របាយការណ៍តាមដានប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ។ ប្រភពព័ត៌មានរួមមានទាំងអង្គការជាតិ និងអង្គការអន្តរជាតិ។ ការពិនិត្យឡើងវិញនូវផ្នែកច្បាប់ និងគោលនយោបាយ បានគ្របដណ្តប់លើឯកសារច្បាប់សំខាន់ៗ រួមមាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ ច្បាប់ស្តីពីរបបសារព័ត៌មាន សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ក្រមព្រហ្មទណ្ឌ អនុក្រឹត្យ ព្រមទាំងច្បាប់ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀត។



**ការស្ទង់មតិតាមអនឡាញ៖** ការស្ទង់មតិ បានប្រមូលទិន្នន័យអំពីលក្ខខណ្ឌការងារ ការយល់ឃើញអំពីសេរីភាពសារព័ត៌មាន និងបញ្ហាប្រឈមប្រចាំថ្ងៃក្នុងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។ អ្នកចូលរួមស្ទង់មតិសរុបចំនួន ១០៩ នាក់ (ស្ត្រី ៣៧ នាក់) ក្នុងនោះមានអ្នកសារព័ត៌មានពេញម៉ោងចំនួន ២៦ នាក់ អ្នកសារព័ត៌មានសេរីចំនួន ២៧ នាក់ និងពលរដ្ឋអ្នកសារព័ត៌មានចំនួន ៣៤ នាក់ ព្រមទាំងនិពន្ធនាយក និងបុគ្គលិកផ្នែកប្រព័ន្ធផ្សព្វផ្សាយផ្សេងដ៏ទៃទៀត។ ក្នុងចំណោមចំនួនសរុបនេះមាន ៤៥ នាក់រស់នៅរាជធានីភ្នំពេញ និង ៦៤ នាក់រស់នៅបណ្តាខេត្តផ្សេងៗ។



**កិច្ចពិភាក្សាក្រុម៖** ត្រូវបានធ្វើឡើងដើម្បីប្រមូលទស្សនៈរួម អំពីបញ្ហាប្រឈមប្រចាំថ្ងៃ ឧបសគ្គផ្នែកច្បាប់ និងគោលនយោបាយ ព្រមទាំងបទពិសោធន៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រក្នុងវិស័យសារព័ត៌មាន។ កិច្ចពិភាក្សាចំនួន៤ក្រុម ត្រូវបានរៀបចំឡើងជាមួយក្រុមអ្នកសារព័ត៌មានផ្សេងៗគ្នា ក្នុងនោះរួមមាន អ្នកសារព័ត៌មានជាស្ត្រី អ្នកសារព័ត៌មានសេរី ពលរដ្ឋអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានមកពីស្ថាប័នសារព័ត៌មានដែលបានចុះបញ្ជី។



**ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ៖** ការសម្ភាសស៊ីជម្រៅដើម្បីស្វែងយល់អំពីទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ន ក្នុងកិច្ចសម្ភាសន៍នោះសរុបមានចំនួន ៩ ក្រុម ក្នុងនោះរួមមាន អ្នកតំណាងមកពីស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ស្ថាប័នសារព័ត៌មាន និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការលើការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយ និងផ្តល់ការគាំទ្រដល់អ្នកសារព័ត៌មាន។

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រជ្រើសរើសគំរូសំណាក ដោយវិធីសាស្ត្រជ្រើសរើសគំរូដោយចេតនា ។ អ្នកចូលរួមក្នុងសិក្សានេះ ត្រូវបានជ្រើសរើសដោយផ្អែកលើចំណេះដឹង បទពិសោធន៍ និងភាពពាក់ព័ន្ធរបស់ពួកគាត់ចំពោះប្រធានបទស្រាវជ្រាវ។ ក្រុមអ្នកចូលរួមទាំងនេះរួមមាន អ្នកអនុវត្តការងារផ្នែកប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល អ្នកអនុវត្តបទប្បញ្ញត្តិ និងអ្នកសិក្សាស្រាវជ្រាវ។

ទិន្នន័យដែលទទួលបានពីកិច្ចពិភាក្សាក្រុម និងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ត្រូវបានវិភាគដោយប្រើវិធីសាស្ត្រវិភាគតាមបែបក្រុមនៃប្រធានបទ។ វិធីសាស្ត្រនេះត្រូវបានប្រើដើម្បីស្វែងយល់ និងបកស្រាយប្រធានបទ និងនិន្នាការនៃបញ្ហាដែលជារឿយៗកើតឡើងជាបន្តបន្ទាប់ និងមានភាពពាក់ព័ន្ធរបស់បញ្ហានោះនៅក្នុងការរាយការណ៍។ ទិន្នន័យពីការស្ទង់មតិត្រូវបានវិភាគ ដោយប្រើកម្មវិធីស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម។ ការវិភាគនេះបានកំណត់និន្នាការ និងភាពទំនាក់ទំនងគ្នា។ លទ្ធផលនៃទិន្នន័យ ត្រូវបានបង្ហាញតាមរយៈក្រាហ្វិក គំនូសតាង និងតារាង ដោយប្រើទិន្នន័យជាភាគរយ ដើម្បីបង្ហាញអំពីបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

## ដែនកំណត់

ការស្ទង់មតិបានចាប់ផ្តើមចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦ ក្នុងចំណោមអ្នកសារព័ត៌មាន អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មាន។ ក្នុងអំឡុងពេលនៃការប្រមូលទិន្នន័យមានបញ្ហាប្រឈមខ្លះៗបានកើតឡើងដែលអាចប៉ះពាល់ដល់ទាំងការប្រមូលទិន្នន័យ និងភាពជាតំណាងនៃចំណុចគន្លឹះនីមួយៗ។ គួរកត់សម្គាល់ថា អ្នកសារព័ត៌មានដែលរស់នៅតំបន់មួយចំនួននៃខេត្តប្រឈមនឹងការតភ្ជាប់អ៊ីនធឺណិតដែលរារាំងពួកគេក្នុងការបំពេញការស្ទង់មតិ។ ការចូលរួមមានកម្រិតទាបក៏ត្រូវបានរាយការណ៍ក្នុងចំណោមអ្នកចូលរួមស្ទង់មិត ដែលភាគច្រើនមានការចូលរួមពីបញ្ហាអស្ថិរភាពហិរញ្ញវត្ថុ និងការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនដែលបង្ហាញការពិតជាច្រើនដែលការសិក្សានេះបានកត់ត្រា និងស្វែងរកការដោះស្រាយ។

បញ្ហាទាំងនេះ បូករួមជាមួយដែនកំណត់ទូទៅនៃការសិក្សាត្រូវបានប្រើប្រាស់សម្រាប់ការបកស្រាយទិន្នន័យដែលបានរកឃើញ។ ការសិក្សានេះផ្តោតលើទិដ្ឋភាពរួមរបស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាក្នុងរយៈពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥ ដូច្នេះវាអាចមិនបង្ហាញពីនិន្នាការរយៈពេលវែងនាពេលអនាគតបានពេញលេញនោះទេ។ លើសពីនេះ ភាពមិនស្មើគ្នាអំពីព័ត៌មានភូមិសាស្ត្ររបស់អ្នកចូលរួមស្ទង់មតិ អាចបង្កឱ្យមានភាពខុសគ្នានៃស្ថានភាពរបស់អ្នកសារព័ត៌មាននៅតាមតំបន់ផ្សេងៗ ដែលមិនអាចឆ្លុះបញ្ចាំងបានពេញលេញ។ បន្ថែមពីនេះ ការសិក្សាគឺពឹងផ្អែកជាចម្បងលើទិន្នន័យដែលរាយការណ៍ដោយអ្នកចូលរួមផ្ទាល់ដែលអាចមានភាពលម្អៀងលើទស្សនៈ ឬឆន្ទៈរបស់អ្នកសារព័ត៌មានក្នុងការបង្ហាញបទពិសោធន៍ដែល មានលក្ខណៈរសើប ជាពិសេសក្នុងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលមានការរឹតត្បិត។

លើសពីនេះ បញ្ហាប្រឈមដែលបានរាយការណ៍នៅក្នុងការសិក្សានេះ អាចត្រូវបានវាយតម្លៃកាន់ធ្ងន់ធ្ងរឡើងដោយសារឥទ្ធិពលនៃព្រឹត្តិការណ៍សំខាន់ៗខាងក្រៅដែលកើតឡើងក្នុងអំឡុងពេលស្រាវជ្រាវ។ ព្រឹត្តិការណ៍ទាំងនេះរួមមាន ការកាត់បន្ថយជំនួយថវិកានៅដើមឆ្នាំ២០២៥ ដែលបានរំខានដល់ប្រតិបត្តិការរបស់ស្ថាប័នសារព័ត៌មាន និងធ្វើឱ្យបាត់បង់ការងារស្ទើរតែទាំងស្រុងក្នុងវិស័យនេះ ព្រមជាមួយនឹងបញ្ហាជម្លោះព្រំដែននៅចុងឆ្នាំ២០២៥ ដែលបានបង្កហានិភ័យបន្ថែមលើផ្នែកសុវត្ថិភាពរាងកាយ អស្ថិរភាពហិរញ្ញវត្ថុ និងសម្ពាធផ្លូវចិត្តដល់អ្នកសារព័ត៌មានដែលកំពុងបំពេញបេសកម្មនៅជិតតំបន់ដែលរងផលប៉ះពាល់។

ព្រឹត្តិការណ៍ទាំងនេះ កើតឡើងស្របពេលជាមួយនឹងស្ថានភាពប្រឈមដែលមានស្រាប់ក្នុងវិជ្ជាជីវៈនេះ។ ដូច្នេះលទ្ធផលដែលពាក់ព័ន្ធនឹងកម្រិតភាពតានតឹង សុខភាពផ្លូវចិត្ត និងភាពមិនច្បាស់លាស់ផ្នែកហិរញ្ញវត្ថុ គួរត្រូវបានបកស្រាយដោយពិចារណាលើបរិបទនេះដោយសារវាទំនងជាឆ្លុះបញ្ចាំងទាំងបញ្ហាប្រឈមរ៉ាំរ៉ៃដែលកើតមានទូទាំងវិស័យ និងផលប៉ះពាល់បន្ទាន់ដែលបណ្តាលមកពីវិបត្តិជាក់លាក់ក្នុងរយៈពេលសិក្សានេះ។

## ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ

បរិយាកាសនៃប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ មានស្ថាប័នប្រព័ន្ធផ្សព្វផ្សាយសរុបចំនួន ១,៥៧៥ អង្គភាព ដោយក្នុងនោះទម្រង់ឌីជីថលកំពុងគ្រប់គ្រងវិស័យព័ត៌មាន នេះបើយោងតាមទិន្នន័យឆ្នាំ២០២៥ ដែលបានធ្វើបច្ចុប្បន្នភាព ហើយត្រូវបានផ្សាយនៅក្នុងត្រីមាសទី១ ឆ្នាំ២០២៦។[2] ចំនួននេះរួមមានប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីចំនួន ៦៧៥ អង្គភាព ដូចជា វិទ្យុ ទូរទស្សន៍ ការបោះពុម្ពផ្សាយ និងរោងពុម្ព និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយថ្មីចំនួន ៩០០ អង្គភាព រួមមានគេហទំព័រ ទូរទស្សន៍អនឡាញ សេវាកម្ម OTT និងប្រព័ន្ធផ្សព្វផ្សាយផ្អែកលើប្រព័ន្ធផ្កាយរណប។

ទោះជាយ៉ាងណាក៏ដោយ លំហនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងប្រទេសកម្ពុជានៅតែបន្តប្រឈមនឹងការរឹតត្បិត។ ជាក់ស្តែង តាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក នៅឆ្នាំ២០២៥ កម្ពុជាទទួលចំណាត់ថ្នាក់ទី១៦១ ក្នុងចំណោម ១៨០ ប្រទេស ដែលធ្លាក់ចុះពីចំណាត់ថ្នាក់ទី ១៥១ ក្នុងឆ្នាំ២០២៤។ ក្នុងឆ្នាំនេះដែរអង្គការ CIVICUS Monitor[3] បានវាយតម្លៃលំហសេរីភាពពលរដ្ឋកម្ពុជាស្ថិតក្នុងស្ថានភាពរងការគាបសង្កត់ដោយទទួលបានការវាយតម្លៃពិន្ទុត្រឹម ២៧ពិន្ទុ នៃពិន្ទុ១០០ នៅក្នុងលទ្ធផលសកលឆ្នាំ២០២៥។ ចំណែកឯអង្គការ Freedom House ក៏បានវាយតម្លៃប្រទេសកម្ពុជាថា «មិនសេរី» ដោយទទួលបានការវាយតម្លៃពិន្ទុ ២២ លើ ១០០ ខណៈសេរីភាពលើអ៊ីនធឺណិតត្រូវបានការវាយតម្លៃថា «មានសេរីភាពដោយផ្នែក» ដោយទទួលបានការវាយតម្លៃពិន្ទុ ៤២ លើ ១០០ ក្នុងឆ្នាំ២០២៥។[4]

គិតត្រឹមខែតុលា ឆ្នាំ២០២៥ កម្ពុជាមានអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយដែលបានចុះបញ្ជីចំនួន ៨,៧៣២ នាក់។ ក្នុងចំណោមអ្នកសារព័ត៌មានទាំង ៨,៧៣២ នាក់នេះ មានស្ត្រីត្រឹមតែ ១៣% ប៉ុណ្ណោះ។ ចំនួននេះបានកើនឡើង ៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤។[5]

ក្រៅពីមានស្ថាប័នប្រព័ន្ធផ្សព្វផ្សាយជាច្រើននៅប្រទេសកម្ពុជា ការកើនឡើងនៃអ្នកប្រើប្រាស់អ៊ីនធឺណិតបានធ្វើឱ្យទម្រង់ឌីជីថលក្លាយជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជាភាគច្រើន។[6] គិតត្រឹមដើមឆ្នាំ២០២៥ កម្ពុជាមានអ្នកប្រើប្រាស់អ៊ីនធឺណិតសរុបចំនួន ១០.៨ លាននាក់ (ស្មើនឹង ៦០% នៃប្រជាជន) និងអ្នកប្រើប្រាស់បណ្តាញសង្គមចំនួន ១២.៩ លាននាក់ (ស្មើនឹង ៧២% នៃប្រជាជន)។ ទម្រង់ឌីជីថល

---

[2] «ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាបានកើនដល់ ១,៥៧៥ ស្ថាប័ន ខណៈទម្រង់ឌីជីថលកំពុងគ្រប់គ្រងវិស័យនេះ» ខ្មែរថាមស៍, ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦, https://www.khmertimeskh.com/501888736/cambodia-media-landscape-hits-1575-outlets-as-digital-platforms-dominate-sector/.

[3] «ការតាមដានលំហសង្គមស៊ីវិល», CIVICUS Monitor ឆ្នាំ២០២៥, https://monitor.civicus.org/country/cambodia/.

[4] «សេរីភាពនៅក្នុងពិភពលោក ឆ្នាំ២០២៥», Freedom House ឆ្នាំ២០២៥, https://freedomhouse.org/country/cambodia.

[5] ហ្វ្រេសញូស៍, 'គិតត្រឹមឆ្នាំ២០២៥នេះ កម្ពុជាមានអ្នកសារព័ត៌មានស្ត្រី១៣% ក្នុងចំណោមអ្នកសារព័ត៌មានសរុបជាង៨ពាន់នាក់ ដែលក្រសួងផ្តល់បណ្ណសម្គាល់, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥, https://m.freshnews.com.kh/localnews/409891-2025-11-27-19-25-10

[6] Simon Kemp, «ឌីជីថលឆ្នាំ២០២៥៖ កម្ពុជា», Datareportal, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៥, https://datareportal.com/reports/digital-2025-cambodia.

ដូចជា ហ្វេសប៊ុក និងតិកតុក បានដើរតួនាទីស្នូលក្នុងរបៀបដែលព័ត៌មានត្រូវបានផលិត ចែកចាយ និងប្រើប្រាស់។

ការវិវត្តនេះបានធ្វើឱ្យបរិយាកាសព័ត៌មានកាន់តែស្មុគស្មាញ ដូចដែលបានបង្ហាញដោយលទ្ធផលនៃការសិក្សា។ ការរីករាលដាលនៃព័ត៌មានមិនពិត និងមាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិត បានធ្វើឱ្យការផ្ទៀងផ្ទាត់ព័ត៌មានកាន់តែលំបាក និងបង្កឱ្យមានការព្រួយបារម្ភអំពីភាពត្រឹមត្រូវ និងភាពជឿជាក់នៃព័ត៌មាន។ ដូច្នេះអ្នកសារព័ត៌មានគួរតែទាញយកអត្ថប្រយោជន៍ពីឱកាសដែលបញ្ញាសិប្បនិម្មិតផ្តល់ឱ្យសម្រាប់ផលិតមាតិកាព័ត៌មានដូចជា ឧបករណ៍បម្លែងអត្ថបទទៅជាសំឡេងដែលដំណើរការដោយបញ្ញាសិប្បនិម្មិតដែលអនុញ្ញាតឱ្យទស្សនិកជនអាចស្តាប់អត្ថបទព័ត៌មាននៅលើគេហទំព័រ។ ទោះជាយ៉ាងណាស្ថាប័នសារព័ត៌មានក៏គួរតែបង្កើតគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់បញ្ញាសិប្បនិម្មិតនៅក្នុងស្ថាប័នដែលស្របតាមក្រមសីលធម៌ និងក្រមវិជ្ជាជីវៈសារព័ត៌មាន។

បរិយាកាសនៃវិស័យសារព័ត៌មាន ក៏បានទទួលរងឥទ្ធិពលដោយសម្ពាធពីកត្តាខាងក្រៅផងដែរ ដូចជាស្ថានភាពព្រំដែនកម្ពុជា-ថៃ បានបង្កើនភាពរសើបជុំវិញការរាយការណ៍ព័ត៌មានទាក់ទងនឹងសន្តិសុខជាតិ ដោយការរាយការណ៍ព័ត៌មានត្រូវបានត្រួតពិនិត្យ សាកសួរ ឬជំទាស់កាន់តែតឹងរ៉ឹង។ ការកាត់បន្ថយថវិកាជំនួយអន្តរជាតិក៏បានប៉ះពាល់ដល់និរន្តរភាពរបស់ស្ថាប័នសារព័ត៌មាន ដោយបង្កឱ្យមានការរឹតត្បិតធនធាន និងភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុ។

លទ្ធផលនៃការស្ទង់មតិក្នុងការសិក្សានេះក៏ស្របទៅនឹងការវាយតម្លៃទាំងនេះ ដោយការសិក្សានេះ ក៏បានបង្ហាញពីការធ្លាក់ចុះនៃសេរីភាពសារព័ត៌មាននៅឆ្នាំ២០២៥ ផងដែរ។ នៅក្នុងរបាយការណ៍នេះ អ្នកសារព័ត៌មានចំនួន ១០៩ នាក់ បានវាយតម្លៃសេរីភាពសារព័ត៌មាននៅកម្ពុជាសម្រាប់ឆ្នាំ២០២៥ ជាមធ្យមត្រូវបានវាយតម្លៃត្រឹមតែ ៤.៨២ ពិន្ទុ លើ ១០ ពិន្ទុ។ លទ្ធផលនេះស្របគ្នានឹងរបាយការណ៍ស្តីពី បញ្ហាប្រឈមនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឆ្នាំ២០២៤ ដែលបានរកឃើញថា បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជានៅតែស្ថិតក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងពីរាជរដ្ឋាភិបាល ហើយអ្នកសារព័ត៌មានត្រូវប្រឈមនឹងការចាប់ខ្លួន និងការគំរាមកំហែងផ្នែកច្បាប់ដូចជា ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ និងបទប្បញ្ញត្តិស្តីពីបទបរិហារកេរ្តិ៍នៃក្រមព្រហ្មទណ្ឌ។[7]

ទោះជាយ៉ាងណា លទ្ធផលនៃការរកឃើញទាំងនេះមានភាពខុសគ្នាក្នុងចំណុចមួយចំនួនពីរបាយការណ៍ស្តីពី «ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា ឆ្នាំ២០២៦» របស់ក្រសួងព័ត៌មាន ដែលផ្អែកលើការស្ទង់មតិបែបទូលំទូលាយដែលបង្ហាញថា អ្នកចូលរួមស្ទង់មតិចំនួន ៨៥.៨% បានរាយការណ៍ថា ពួកគេមានសេរីភាពពេញលេញក្នុងការប្រមូលព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានជូនសាធារណជន។[8] លើសពីនេះអ្នកចូល

---

[7] របាយការណ៍ស្តីពី បញ្ហាប្រឈមប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឆ្នាំ២០២៤ ម.ក.ប.រ ឆ្នាំ២០២៤https://ccimcambodia.org/?page_id=6232

[8] «ក្រសួងព័ត៌មានបញ្ជាក់ថា សេរីភាពសារព័ត៌មាននៅកម្ពុជា ត្រូវបានវាយតម្លៃថា "ល្អ" នៅក្នុងការស្ទង់មតិថ្នាក់ជាតិឆ្នាំ២០២៦» AKP, ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៦, https://akp.gov.kh/post/detail/369037.

រួមស្ទង់មតិចំនួន ៧០.៤% បានបញ្ជាក់ថា ពួកគាត់មិនធ្លាប់ជួបប្រទះការគំរាមកំហែង ការយាយី ឬអំពើហិង្សា ក្នុងអំឡុងពេលបំពេញភារកិច្ចសារព័ត៌មានរបស់ពួកគាត់ក្នុងរយៈពេលមួយឆ្នាំកន្លងមកទេ ខណៈអ្នកចូលរួមស្ទង់មតិចំនួន ៨៤.៦% បានបញ្ជាក់ថា ពួកគាត់មិនធ្លាប់ប្រឈមនឹងចំណាត់ការផ្លូវច្បាប់ពីប្រជាពលរដ្ឋ ឬអាជ្ញាធរពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មាននោះទេ។

## I. ការកើនឡើងនៃបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ និងការពន្យារពេលអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន នាំឱ្យមានការរឹតត្បិតដល់ការទទួលបានព័ត៌មានផ្លូវការ

ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានបន្តវិធានការបទប្បញ្ញត្តិ ដែលរឹតត្បិតសេរីភាពសារព័ត៌មាន ដែលឆ្លុះបញ្ចាំងពីនិន្នាការកាន់តែធ្ងន់ធ្ងរក្នុងការបង្កើនការគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយ។ ទោះបីជា**ច្បាប់ស្តីពីរបបសារព័ត៌មាន** (ឆ្នាំ១៩៩៥) បានធានាជាផ្លូវការអំពីសេរីភាពសារព័ត៌មានក៏ដោយ អាជ្ញាធរជាញឹកញាប់បានយោងបទប្បញ្ញត្តិដែលមាននិយមន័យទូលំទូលាយនៃ**ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** (ឆ្នាំ២០០៩) ដើម្បីចាត់វិធានការផ្លូវច្បាប់មកលើអ្នកសារព័ត៌មាន។ មាត្រាសំខាន់ៗ ដែលត្រូវបានប្រើប្រាស់មកលើអ្នកសារព័ត៌មានរួមមាន មាត្រា ៤៩៤ និង ៤៩៥ ស្តីពីបទញុះញង់។[9] មាត្រាទាំងនេះត្រូវបានប្រើជាញឹកញាប់ក្នុងករណីពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មានលើបញ្ហានយោបាយ បរិស្ថាន ឬបញ្ហាសង្គមដែលមានភាពរសើប។

អ្នកសារព័ត៌មានក៏ត្រូវបានចោទប្រកាន់ក្រោមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ រួមមានមាត្រា ៣០៥ ស្តីពីបទបរិហារកេរ្តិ៍ មាត្រា ៣០៧ ស្តីពីការប្រមាថជាសាធារណៈ មាត្រា ៥២៣ ស្តីពីបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ និងមាត្រា ៤៤៥ ស្តីពីបទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ ដែលធ្វើឱ្យអន្តរាយដល់ការការពារជាតិ។ បទប្បញ្ញត្តិទាំងនេះ កំណត់ទោសចំពោះការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ សេចក្តីថ្លៃថ្នូរ ឬឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ បទប្បញ្ញត្តិទាំងនេះ ក៏បានបង្កឱ្យមានការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មាន ដែលជារឿយៗនាំឱ្យមានការពិន័យ ការឃុំខ្លួន ឬការដាក់ពន្ធនាគារ។

បទប្បញ្ញត្តិថ្មីៗ ក៏បានប៉ះពាល់ដល់សមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការបំពេញការងារដោយសេរី និងការទទួលបានលិខិតសម្គាល់ផ្លូវការផងដែរ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៥ ក្រសួងព័ត៌មានបានដាក់ឱ្យអនុវត្ត**ប្រកាសស្តីពី«គុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន សម្រាប់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍»**។ វិធានការនេះបានកំណត់លក្ខខណ្ឌតឹងរ៉ឹងជាងមុនសម្រាប់ការចុះបញ្ជីបណ្ណសារព័ត៌មាន។[10] លក្ខខណ្ឌទាំងនេះរួមមាន គុណវុឌ្ឍិផ្នែកអប់រំ ការពិនិត្យប្រវត្តិបទល្មើស និងលិខិតបញ្ជាក់អំពីអាកប្បកិរិយាល្អពីអាជ្ញាធរមូលដ្ឋាន។ ទោះបីជាវិធានការនេះមានគោលបំណងលើកកម្ពស់វិជ្ជាជីវៈក្នុងវិស័យសារព័ត៌មានក៏ដោយ សម្ព័ន្ធអង្គការសង្គមស៊ីវិល និងអង្គការធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញការព្រួយបារម្ភថា លក្ខខណ្ឌទាំងនេះអាចនាំឱ្យមានការរឹតត្បិតបន្ថែមទៀតលើសេរីភាពប្រព័ន្ធផ្សព្វផ្សាយ។[11] វាក៏អាចធ្វើឱ្យការ

---

[9] «ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា», មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ខែវិច្ឆិកា ឆ្នាំ២០២២, https://media.business-humanrights.org/media/documents/CCHR_Report_on_State_of_Freedom_of_Expression_and_Access_to_Information_FINAL__mxbgkOy.pdf

[10] ឃួន ណារីម, «បទប្បញ្ញត្តិថ្មីសម្រាប់អ្នកសារព័ត៌មាន រឹតបន្តឹងការគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា» ខេមបូចា, ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៥, https://cambojanews.com/new-regulations-for-journalists-tighten-grip-on-cambodias-media/

[11] «ប្រកាសថ្មី ខ្វះការពិគ្រោះយោបល់ និងរឹតត្បិតសេរីភាពប្រព័ន្ធផ្សព្វផ្សាយបន្ថែមទៀត», លីកាដូ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥, https://www.licadho-cambodia.org/pressrelease.php?perm=552

របាយការណ៍ព័ត៌មានកាន់តែលំបាកសម្រាប់អ្នកសារព័ត៌មានឯករាជ្យ អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានដែលកំពុងស្វែងរកលិខិតសម្គាល់សារព័ត៌មានជាផ្លូវការ។

ការវិវត្តផ្នែកច្បាប់ និងបទប្បញ្ញត្តិទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងទាំងនៅក្នុងការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះៗ និងលទ្ធផលនៃការស្ទង់មតិ។ អ្នកចូលរួមបទសម្ភាស បានបង្ហាញពីការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីការកើនឡើងនៃការប្រើប្រាស់**ក្រមព្រហ្មទណ្ឌ**ក្នុងការចោទប្រកាន់អ្នកសារព័ត៌មាន។ ការអនុវត្តនេះជាញឹកញាប់បានរំលងការការពារ ដែលមានចែងនៅក្នុង**ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥** ដែលមិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃសារព័ត៌មានឌីជីថល និងទម្រង់អនឡាញ។ អ្នកចូលរួមបទសម្ភាសក៏បានកត់សម្គាល់ផងដែរថា **សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន** ដែលបានរំពឹងទុកជាយូរមកហើយនៅតែមិនទាន់អនុម័ត ជាកត្តាកម្រិតសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការទទួលបានព័ត៌មានផ្លូវការ ផ្ទុយពីការលើកឡើងរបស់អតីតនាយករដ្ឋមន្ត្រីដែលរំពឹងថាច្បាប់នេះនឹងអនុម័តនៅឆ្នាំ២០២៤ ឬឆ្នាំ២០២៥ ។

នៅឆ្នាំនេះ **អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ** (ឆ្នាំ២០២១) [12] នៅតែជាឧបករណ៍ផ្លូវច្បាប់ដែលបង្កឱ្យមានការព្រួយបារម្ភ ដោយរាជរដ្ឋាភិបាលអាចប្រើប្រាស់វាដើម្បីបង្កើនការឃ្លាំមើល និងការគ្រប់គ្រងមាតិកា។ បន្ថែមពីនេះ មជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់មិនយកកម្រៃ (ICNL)[13] ក៏បានបង្ហាញពីក្តីព្រួយបារម្ភផ្នែកបទប្បញ្ញត្តិពាក់ព័ន្ធនឹងឈ្មោះដែនជាតិ «.kh» ដែលបានដាក់កម្រិតលើបុគ្គល ក្រុមហ៊ុន និងអង្គការនានា ក្នុងការប្រើប្រាស់ឈ្មោះដែនជាតិ .kh ដើម្បីចែករំលែកមាតិកា។ វិធានការទាំងនេះអាចប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ និងអាចអនុញ្ញាតឱ្យមានការត្រួតពិនិត្យ ការគ្រប់គ្រង ការបិទ ឬការផ្អាកមាតិកាអនឡាញកាន់តែច្រើន។ អនុក្រឹត្យនេះក៏អនុញ្ញាតឱ្យអាជ្ញាធរបដិសេធសំណើសុំឈ្មោះដែនជាតិ ដែលត្រូវបានចុះបញ្ជីរួចហើយត្រូវបានរក្សាទុក មានលក្ខណៈប៉ះពាល់ដល់ជំនឿ សាសនា ផ្ទុយនឹងទំនៀមទម្លាប់ ឬមិនស្របតាមច្បាប់ផងដែរ។

ថ្មីៗនេះរាជរដ្ឋាភិបាលបានអំពាវនាវដល់អង្គការសង្គមស៊ីវិលដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងយុទ្ធសាស្រ្តជាតិស្តីពីបញ្ញាសិប្បនិម្មិត ដែលនេះបង្ហាញពីពេលវេលាដ៏សាកសមបំផុត និងជាឱកាសដ៏សំខាន់ដើម្បីធានាថាផលប្រយោជន៍ និងតម្រូវការផ្នែកប្រព័ន្ធផ្សព្វផ្សាយត្រូវបានបង្ហាញនៅក្នុងគោលនយោបាយនេះ។ នៅពេលយុទ្ធសាស្រ្តបច្ចេកវិទ្យាថ្មី AI ត្រូវបានដាក់ចេញជាផ្លូវការវានឹងមានសារៈសំខាន់ដល់អ្នកសារព័ត៌មាន រួមទាំងអ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានដែលត្រូវតែមានចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់ AI ឱ្យមានប្រសិទ្ធិភាព និងការទទួលខុសត្រូវក្នុងបរិបទការងាររបស់ពួកគេ ជំនួសការមិនអើពើដែលនាំហានិភ័យ និងការមិនបានប្រើប្រាស់ទៅវិញ។

---

[12] «កម្ពុជា៖ ពង្រីកការត្រួតពិនិត្យ និងការគ្រប់គ្រងអ៊ីនធឺណិត», Human Rights Watch, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១, https://www.hrw.org/news/2021/02/18/cambodia-internet-censorship-control-expanded

[13] «ការវិភាគផ្នែកច្បាប់៖ អនុក្រឹត្យស្តីពីឈ្មោះដែនជាតិ», អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២, https://nepcambodia.org/2022/06/22/legal-analysis-cambodias-sub-decree-on-national-domain-names/

នៅក្នុងន័យនេះ ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានតួនាទីសំខាន់ខ្លាំងណាស់។ ក្រសួងទាំងពីរគួរសហការបណ្ដុះបណ្ដាលអក្ខរកម្ម AI ដល់អ្នកសារព័ត៌មានទាំងអស់ដែលវានឹងជួយដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ ជាមួយនឹងពេលវាលាជាក់លាក់ មានធនធានបម្រុងទុក និងគោលដៅដែលអាចវាស់វែងបាន។ គួរមានការរៀបចំផែនការជាក់លាក់ និងទម្រង់បណ្ដុះបណ្ដាលដែលមិនត្រឹមតែរាប់បញ្ចូលតែបុគ្គលិកផ្នែកសារព័ត៌មានប៉ុណ្ណោះទេ តែត្រូវរាប់បញ្ចូលទាំងអ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានផងដែរ នោះទើបបង្កើនភាពសកម្មក្នុងប្រព័ន្ធអេកូសារព័ត៌មាន ដោយឡែកគំនិតផ្ដួចផ្ដើមការកសាងសមត្ថភាពនេះ នៅមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយទេ។

**ប្រកាសលេខ ០៨៥ ស្ដីពី «ការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន»**[14] នៅខែសីហា ឆ្នាំ ២០២៤ ក៏បានទទួលរងការរិះគន់ពីអ្នកសារព័ត៌មាន និងអ្នកសង្កេតការណ៍ប្រព័ន្ធផ្សព្វផ្សាយ។ ប្រកាសនេះត្រូវបានរាយការណ៍ថា បានដាក់ឱ្យអនុវត្តដោយមិនមានការពិគ្រោះយោបល់សមស្របជាមុន។ ទោះបីជាវាត្រូវបានបង្ហាញថា ជាឧបករណ៍សម្រាប់លើកកម្ពស់ក្រមសីលធម៌ក៏ដោយ ការប្រើប្រាស់ភាសាដែលមិនច្បាស់លាស់ វិសាលភាពទូលំទូលាយរបស់វា ដែលរួមបញ្ចូលទាំងអ្នកប្រើប្រាស់បណ្ដាញសង្គម និងសក្ដានុពលនៃការអនុវត្តដ៏ទូលាយ បានបង្កឱ្យមានការព្រួយបារម្ភថា វាអាចត្រូវបានប្រើប្រាស់សម្រាប់ការឃ្លាំមើល និងការគ្រប់គ្រង ជាជាងសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ។ ជាមួយនឹងក្ដីបារម្ភទាំងនេះ ការអនុវត្តធម្មនុញ្ញនេះមិនគួរមានភាពប្រញាប់ប្រញាល់នោះទេ។ ផ្ទុយទៅវិញគួរមានការផ្អាកដើម្បីអនុញ្ញាតឱ្យមានការពិភាក្សាពេញលេញប្រកបដោយអត្ថន័យ និងចម្រុះបែបពីគ្រប់ភាគីពាក់ព័ន្ធ។ អ្នកជំនាញរបស់អង្គការសហប្រជាជាតិ ក៏បានអំពាវនាវឱ្យផ្អាកការអនុវត្តធម្មនុញ្ញនេះ និងផ្ដល់អនុសាសន៍ថាគ្រប់ដំណើរការពាក់ព័ន្ធនឹងក្រមវិជ្ជាជីវៈសារព័ត៌មានត្រូវតែមានភាពចម្រុះ មានការចូលរួម និងវិវត្តន៍ក្នុងពេលវេលាសមស្របណាមួយដោយមានការត្រួតពិនិត្យ និងផ្ដល់មតិត្រលប់។ ការបន្តឱ្យអនុវត្តដោយមិនបានដោះស្រាយបញ្ហានីតិវិធីជាមូលដ្ឋាននេះ មិនយូរមិនឆាប់វានឹងធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងរាជរដ្ឋាភិបាល និងវិស័យសារព័ត៌មាននៅពេលដែលមានការជជែកដេញដោល ឬនៅពេលត្រូវទទួលខុសជាក់លាក់ណាមួយ។

អ្នកសារព័ត៌មាន នៅតែមានការប្រុងប្រយ័ត្នចំពោះហានិភ័យ ដែលបង្កឡើងដោយយន្តការផ្លូវច្បាប់ និងបទប្បញ្ញត្តិ ដែលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ។ នៅក្នុងក្របខណ្ឌបទប្បញ្ញត្តិ ក្ដីបារម្ភសំខាន់ៗ រួមមាន ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ (៦៦%) ការពន្យារពេលក្នុងការអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន (៦០%) និងការប្រើប្រាស់បទប្បញ្ញត្តិព្រហ្មទណ្ឌ ដែលមាននិយមន័យទូលំទូលាយទាក់ទងនឹងសណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ (៥៩%)។

---

[14] ស៊ើង និមល់, «ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានថ្មី ត្រូវបានអនុវត្តយ៉ាងឆាប់រហ័ស ត្រឹមតែប៉ុន្មានថ្ងៃបន្ទាប់ពីផុតកំណត់ទទួលយោបល់», ខេមបូចាព័ត៌មាន, ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤, https://cambojanews.com/new-professional-journalism-charter-speedily-implemented-only-days-after-input-deadline/

អ្នកសារព័ត៌មានមានការព្រួយបារម្ភជាពិសេសចំពោះការបកស្រាយយ៉ាងទូលំទូលាយលើមាត្រាមួយចំនួននៃច្បាប់ ដែលអាចត្រូវបានប្រើប្រាស់ដោយមានគោលបំណងរឹតត្បិតដល់ការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន។ អ្នកផ្តល់ព័ត៌មានគន្លឹះបានកត់សម្គាល់ថា បទល្មើសទាំងនោះមានដូចជា បទល្មើសញុះញង់ និងបទបរិហារកេរ្តិ៍ ជាញឹកញាប់ត្រូវបានអនុវត្តក្នុងរបៀបដែលធ្វើឱ្យអ្នកសារព័ត៌មានប្រឈមនឹងទណ្ឌកម្មធ្ងន់ធ្ងរ និងបង្កឱ្យមានការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មាន។ ក្តីបារម្ភនេះមានកាន់តែខ្លាំងក្រោយការប្រើប្រាស់បទប្បញ្ញត្តិពាក់ព័ន្ធនឹងសន្តិសុខជាតិ រួមមានមាត្រា ៤៤៥ នៃក្រមព្រហ្មទណ្ឌស្តីពី «បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ ដែលធ្វើឱ្យអន្តរាយដល់ការការពារជាតិ» ដែលក្រោមមាត្រានេះ អ្នកសារព័ត៌មានពីរនាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៤ ឆ្នាំ ពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មានអំពីជម្លោះតាមព្រំដែនកម្ពុជា-ថៃ កាលពីខែធ្នូ ឆ្នាំ២០២៥។[15]

15 «កម្ពុជា៖ អ្នកសារព័ត៌មានពីរនាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៤ ឆ្នាំ ក្រោមច្បាប់ស្តីពីបទក្បត់ជាតិ», សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦, https://www.ifj.org/media-centre/news/detail/category/press-releases/article/cambodia-two-journalists-jailed-for-14-years-under-treason-law

## II. របកគំហើញទី១៖ បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានឯករាជ្យ

គ្រប់របកគំហើញទាំងអស់នៃការសិក្សានេះ គឺផ្អែកលើទិន្នន័យដែលប្រមូលបានតាមរយៈការស្ទង់មតិតាមអនឡាញជាមួយអ្នកសារព័ត៌មាន ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ កិច្ចពិភាក្សាក្រុម និងការស្រាវជ្រាវលើឯកសារដែលមានស្រាប់។ លទ្ធផលនៃការស្ទង់មតិបានបង្ហាញថា ព័ត៌មានមិនពិត និងព័ត៌មានបំភាន់ បានក្លាយជាបញ្ហាប្រឈមសំខាន់ៗដែលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានកំពុងប្រឈមក្នុងឆ្នាំ២០២៥។ បន្ទាប់ពីនេះគឺការព្រួយបារម្ភអំពីនិរន្តរភាពផ្នែកហិរញ្ញវត្ថុរបស់ស្ថាប័នសារព័ត៌មាន។ អ្នកសារព័ត៌មានក៏បានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងការរើសអើងពីសំណាក់អាជ្ញាធរ ការលំបាកក្នុងការទាក់ទងប្រភព ព័ត៌មានសម្រាប់ការសម្ភាស និងសម្ពាធនយោបាយដែលកំពុងកើនឡើង។

លើសពីនេះបញ្ហាប្រឈមផ្សេងទៀតដូចជា ការសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ ការត្រួតពិនិត្យ និងរឹតត្បិតលើប្រព័ន្ធឌីជីថលដោយរាជរដ្ឋាភិបាលក្រោមការអះអាងថាជាកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ហើយស្ថាប័នសារព័ត៌មានជួបការលំបាកក្នុងការទាក់ទាញទស្សនិកជន ខណៈពេលដែលស្ថាប័នទាំងនោះត្រូវរក្សាបាននូវសុចរិតភាពវិជ្ជាជីវៈសារព័ត៌មាន។ អ្នកសារព័ត៌មានក៏បានរាយការណ៍បន្ថែមអំពីឧបសគ្គក្នុងការទទួលបានបណ្ណព័ត៌មាន ការកើនឡើងនៃការប្រកួតប្រជែងរវាងស្ថាប័នសារព័ត៌មាន និងការលំបាករបស់អ្នកសារព័ត៌មានសេរីក្នុងការស្វែងរកថវិកាគាំទ្រ ព្រមទាំងការលំបាកក្នុងការទទួលបានអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ។ អ្នកចូលរួមស្ទង់មតិមួយចំនួនក៏បានលើកឡើងថា មានការជ្រៀតជ្រែកពីម្ចាស់ស្ថាប័នសារព័ត៌មានដែលបានរឹតត្បិតឯករាជ្យភាពក្នុងការរាយការណ៍ព័ត៌មាន។

### ១.១. សកម្មភាពនៃការដាក់សម្ពាធ និងការរឹតត្បិតលើការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន នៅតែបន្តកើតឡើង

នៅឆ្នាំ២០២៥ ម.ក.ប.រ បានកត់ត្រាឧបទ្ទវហេតុចំនួន ៣៤ ករណី ដែលពាក់ព័ន្ធនឹងអ្នកសារព័ត៌មានចំនួន៤៤ នាក់ រួមមានទាំងអ្នកសារព័ត៌មានវិជ្ជាជីវៈ និងពលរដ្ឋអ្នកសារព័ត៌មាន ក្នុងនោះមានពលរដ្ឋអ្នកសារព័ត៌មានជាស្ត្រីចំនួន ៣ នាក់។ ករណីទាំងនេះពាក់ព័ន្ធនឹងការរំលោភបំពានជាច្រើនប្រភេទដូចជា ការការបៀតបៀនផ្លូវភេទ ការគំរាមកំហែងផ្នែកច្បាប់ ការទាមទារឱ្យដកខ្លឹមសារព័ត៌មាន ការឃុំខ្លួន ការបំភិតបំភ័យការដកហូតអាជ្ញាបណ្ណ និងការចាប់ខ្លួនបន្ទាប់ពីការរាយការណ៍ព័ត៌មានអំពីជម្លោះតាមព្រំដែន។ អ្នកសារព័ត៌មានក៏បានប្រឈមនឹងហានិភ័យផ្នែកសុវត្ថិភាពរាងកាយដូចជា ការគំរាមកំហែង និងការបំភិតបំភ័យ ក្នុងអំឡុងពេលចុះយកព័ត៌មាននៅទីតាំងជាក់ស្តែង។

ការប្រើប្រាស់វិធានការផ្នែកច្បាប់ និងផ្នែករដ្ឋបាលដើម្បីប្រឆាំងនឹងអ្នកសារព័ត៌មានបានបង្កជាបញ្ហាប្រឈមធ្ងន់ធ្ងរដោយចំនួនឧបទ្ទវហេតុដែលបានកត់ត្រាមានការកើនឡើងប្រមាណជិត ៣៦% បើប្រៀបធៀបទៅនឹងតួលេខដែលបានរាយការណ៍នៅក្នុងរបាយការណ៍ឆ្នាំ២០២៤។[16]

[16] «របាយការណ៍ស្តីពី បញ្ហាប្រឈមប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឆ្នាំ២០២៤ (ភាសាអង់គ្លេស)» ម.ក.ប.រ, ឆ្នាំ២០២៤, https://ccimcambodia.org/?page_id=6232.

ជាក់ស្តែងនៅខែធ្នូ ឆ្នាំ២០២៥ អ្នកសារព័ត៌មានកម្ពុជាពីរនាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៤ ឆ្នាំពីបទក្បត់ជាតិ បន្ទាប់ពីបានបង្ហាញខ្លួនក្នុងរូបថតជាមួយទាហានកម្ពុជានៅក្បែរតំបន់ព្រំដែនកម្ពុជា-ថៃ ដែលមានជម្លោះ។[17] អ្នកសារព័ត៌មានទាំងពីររូបនេះរួមមាន លោក **ផន សុភាព** អ្នកសារព័ត៌មានរបស់ Battambang Post TV Online និងលោក **ភាព ភារ៉ា** អ្នកសារព័ត៌មានរបស់ TSP 68 TV Online ត្រូវបានផ្តន្ទាទោសក្រោម មាត្រា ៤៤៥ ស្តីពីបទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលធ្វើឱ្យអន្តរាយដល់ការការពារជាតិ។ ការចោទប្រកាន់នេះ ពាក់ព័ន្ធទៅនឹងការបង្ហោះនៅលើបណ្តាញសង្គមហ្វេសប៊ុក ក្នុងអំឡុងពេលរាយការណ៍ព័ត៌មានអំពីជម្លោះព្រំដែន។ បច្ចុប្បន្នអ្នកសារព័ត៌មានទាំងពីរនាក់នៅតែស្ថិតក្នុងការឃុំខ្លួននៅពន្ធនាគារខេត្តសៀមរាប។ ខ្លឹមសារជាក់លាក់ដែលនាំឱ្យមានការចាប់ខ្លួននៅមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ ប៉ុន្តែរូបថតរបស់ពួកគាត់ជាមួយទាហានកម្ពុជានៅក្បែរប្រាសាទតាក្របី ត្រូវបានភ្ជាប់ជាមួយនឹងករណីនេះ។

នៅខែសីហា ឆ្នាំ២០២៥ អ្នកសារព័ត៌មាន លោក **មាស សារ៉ា** ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់ ក្រោយពីបានផ្សាយផ្ទាល់ពីបទសម្ភាសន៍ជាមួយប្រជាពលរដ្ឋនៅក្នុងភូមិមួយតាមតំបន់ព្រំដែនក្នុងអំឡុងពេលមានភាពតានតឹងរវាងប្រជាពលរដ្ឋកម្ពុជា និងយោធាថៃ។[18]

កាលថ្ងៃទី៥ ខែមករា ឆ្នាំ២០២៥ លោក **Gerald Flynn** អតីតប្រធានក្លឹបសារព័ត៌មានបរទេសប្រចាំកម្ពុជា និងជាអ្នកសារព័ត៌មានស៊ើបអង្កេត និងបរិស្ថានដែលមានបទពិសោធន៍យូរឆ្នាំ ត្រូវបានបដិសេធមិនឱ្យចូលប្រទេសកម្ពុជាវិញនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប បន្ទាប់ពីបានធ្វើដំណើរទៅក្រៅប្រទេស។[19]

ហេតុការណ៍នេះបង្ហាញពីសញ្ញានៃការរឹតបន្តឹង ដែលអាចកាន់តែខ្លាំងឡើងលើវត្តមានរបស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិនៅកម្ពុជា ជាពិសេសផ្តោតលើអ្នកសារព័ត៌មានដែលរាយការណ៍បែបស៊ើបអង្កេត និងព័ត៌មានអំពីបញ្ហាបរិស្ថាន។ វាក៏បានបង្កើនការព្រួយបារម្ភអំពីការប្រើប្រាស់វិធានការអន្តោប្រវេសន៍ដើម្បីរឹតត្បិតការរាយការណ៍ព័ត៌មានបែបរិះគន់ផងដែរ។ បញ្ហានេះអាចមានផលប៉ះពាល់កាន់តែទូលំទូលាយទៅលើលំហូរព័ត៌មាន ការត្រួតពិនិត្យពីសហគមន៍អន្តរជាតិ និងបរិយាកាសការងាររបស់អ្នកសារព័ត៌មានបរទេស។

---

[17] «សាលាឧទ្ធរណ៍តម្កល់សាលក្រមផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១៤ ឆ្នាំ សម្រាប់អ្នកសារព័ត៌មានពីរនាក់», លីកាដូ, ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦, https://www.licadho-cambodia.org/flashnews.php?perm=512

[18] «អ្នកសារព័ត៌មានម្នាក់ត្រូវបានចាប់ខ្លួនពីបទផ្សាយផ្ទាល់នៅតាមព្រំដែនថៃ–កម្ពុជា», លីកាដូ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៥, https://www.licadho-cambodia.org/flashnews.php?perm=458.

[19] «សេចក្តីថ្លែងការណ៍រួម៖ អ្នកសារព័ត៌មានបរិស្ថានជនជាតិអង់គ្លេសត្រូវបានបដិសេធមិនឱ្យចូលប្រទេសកម្ពុជាវិញ», OPCC, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥, https://opc-cambodia.org/blog/2025/02/04/joint-statement-british-environmental-journalist-denied-re-entry-to-cambodia/

## ១.២. ភាគច្រើននៃអ្នកសារព័ត៌មានបានអនុវត្តការដាក់កំហិតខ្លួនឯងក្នុងឆ្នាំ២០២៥



តួលេខទី១៖ មូលហេតុនៃការដាក់កំហិតខ្លួនឯងរបស់អ្នកសារព័ត៌មាន

ទិន្នន័យពីការស្ទង់មតិបានបង្ហាញថា អ្នកសារព័ត៌មានចំនួន ៦៣% (៦៩ នាក់ ក្នុងចំណោម ១០៩ នាក់) បានអនុវត្តការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មាន ដោយជៀសវាងការលើកយកប្រធានបទមួយចំនួន។ មូលហេតុចម្បងនៃការដាក់កំហិតខ្លួនឯងនេះ គឺបណ្តាលមកពីការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន។

ប្រមាណ ៤១% (៤៥ នាក់ ក្នុងចំណោម ១០៩ នាក់) នៃអ្នកចូលរួមស្ទង់មតិ បានរាយការណ៍ថា ពួកគាត់មានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់ខ្លួន បន្ទាប់ពីការរាយការណ៍ព័ត៌មានដែលមានភាពរសើប។ ចំណែក ៣៨% ផ្សេងទៀតបានបញ្ជាក់ថា ពួកគាត់អនុវត្តការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មានដោយសារការព្រួយបារម្ភអំពីការបកស្រាយច្បាប់ក្នុងន័យទូលាយពាក់ព័ន្ធនឹងការញុះញង់ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ដែលជាញឹកញាប់ត្រូវបានប្រើប្រាស់មកលើអ្នកសារព័ត៌មាននៅពេលរាយការណ៍លើប្រធានបទដែលមានភាពចម្រូងចម្រាស។ អ្នកសារព័ត៌មានក៏បានរាយការណ៍ផងដែរថា ការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មាននេះក៏បណ្តាលមកពីសម្ពាធពីអាជ្ញាធរ និងភាគីរាជរដ្ឋាភិបាល (៣៦% ឬ ៣៩នាក់ ក្នុងចំណោម ១០៩ នាក់) និងការភ័យខ្លាចចំពោះការចោទប្រកាន់តាមច្បាប់បរិហារកេរ្តិ៍ (៣៦% ឬ ៣៩ នាក់ ក្នុងចំណោម ១០៩ នាក់)។ កត្តាផ្សេងទៀតដែលនាំឱ្យមានការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មានរួមមាន ការព្រួយបារម្ភអំពីការសងសឹកបន្ទាប់ពីការផ្សព្វផ្សាយព័ត៌មាន ការបាត់បង់សិទ្ធិ ឬបណ្ណសារព័ត៌មាន និងសម្ពាធពីម្ចាស់ស្ថាប័នសារព័ត៌មាន (តួលេខទី១)។

ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះក៏បានបង្ហាញផងដែរថា ការដាក់កំហិតខ្លួនឯងក្នុងការរាយការណ៍ព័ត៌មានជាញឹកញាប់ត្រូវបានប្រើជាមធ្យោបាយសម្រាប់អ្នកសារព័ត៌មានក្នុងការគ្រប់គ្រងហានិភ័យជាច្រើនរួមមាន ហានិភ័យលើសុវត្ថិភាពរាងកាយ ផលវិបាកផ្នែកច្បាប់ដែលពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មាន និងការគំរាមកំហែងផ្នែកសុវត្ថិភាពឌីជីថល។ ក្នុងករណីខ្លះ អ្នកសារព័ត៌មានជ្រើសរើសមិនផ្សព្វផ្សាយព័ត៌មាន

មួយចំនួនដែលអាចមានហានិភ័យខ្ពស់។ អ្នកផ្តល់បទសម្ភាសក៏បានបន្ថែមទៀតថា អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានច្រើនប្រឈមនៅពេលរាយការណ៍ព័ត៌មានអំពីបញ្ហានយោបាយដែលមានភាពរសើប ដូចជា អំពើពុករលួយ សន្តិសុខជាតិ ជម្លោះព្រំដែន និងគម្រោងអភិវឌ្ឍន៍ដែលមានភាពចម្រូងចម្រាស។ ក្នុងអំឡុងពេលមានភាពតានតឹងផ្នែកនយោបាយ អ្នកសារព័ត៌មានតែងតែតាមដានយ៉ាងជិតដិតចំពោះការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះការរាយការណ៍ព័ត៌មានរបស់ពួកគាត់ ដោយសារការរាយការណ៍បែបរិះគន់អាចត្រូវបានបកស្រាយថាជាការបង្កផលប៉ះពាល់ដល់សន្តិសុខជាតិ។

## ១. ៣. ៩៤%នៃអ្នកសារព័ត៌មានបង្ហាញថាមានការព្រួយបារម្ភអំពីសុវត្ថិភាព



តួលេខទី២៖ ការព្រួយបារម្ភអំពីសុវត្ថិភាពក្នុងចំណោមអ្នកសារព័ត៌មាន

៩៤% (១០៤ នាក់ ក្នុងចំណោម ១០៩ នាក់) នៃអ្នកសារព័ត៌មានដែលចូលរួមការស្ទង់មតិបានរាយការណ៍ថា ពួកគាត់ព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនអំឡុងពេលបំពេញការងារជាអ្នកសារព័ត៌មានឯករាជ្យ (តួលេខទី២)។ ជារួមមកការបង្ហាញពីការព្រួយបារម្ភអំពីសុវត្ថិភាពរបស់អ្នកសារព័ត៌មានឯករាជ្យបានឆ្លុះបញ្ចាំងពីបរិយាកាសដ៏គួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់សេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ ការភ័យខ្លាចទាំងនេះមិនត្រឹមតែគំរាមកំហែងដល់សុខុមាលភាពបុគ្គលដែលប្តេជ្ញាចិត្តក្នុងការស្វែងរកការពិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មានដែលគួរឱ្យទុកចិត្ត និងចម្រុះផងដែរ។

## ១. ៤. អ្នកសារព័ត៌មានភាគច្រើនបានបង្ហាញការព្រួយបារម្ភអំពីហានិភ័យជាប់ពន្ធនាគារ និងវិធានការផ្លូវច្បាប់ផ្សេងៗ

តួលេខទី៣៖ ប្រភេទនៃការគំរាមកំហែងផ្នែកសុវត្ថិភាពដែលអ្នកសារព័ត៌មានបានជួបប្រទះ



អ្នកចូលរួមស្ទង់មតិចំនួន ៦៩% (៧៧ នាក់ក្នុងចំណោម ១០៩ នាក់) បានរាយការណ៍ពីការព្រួយបារម្ភអំពី «ការគំរាមកំហែងនៃការជាប់ពន្ធនាគារ ឬការចាត់វិធានការផ្លូវច្បាប់» ខណៈដែល ៦៨% (៧៥ នាក់ក្នុងចំណោម ១០៩ នាក់) បានលើកឡើងថា «ការឃ្លាំមើលដោយអាជ្ញាធរ ឬបុគ្គលមានអំណាចទាំងដោយផ្ទាល់ និងតាមអនឡាញ» គឺជាបញ្ហាសំខាន់ និងគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង។

បន្ថែមពីនេះ ការឃុំខ្លួន ឬការចាប់ខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ឬគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ត្រូវបានរាយការណ៍ដោយអ្នកសារព័ត៌មានភាគច្រើន ដែលបង្ហាញពីការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរអំពីនីតិវិធី និងការការពារផ្លូវច្បាប់។ ស្រដៀងគ្នានេះដែរ អ្នកចូលរួមស្ទង់មតិចំនួនច្រើនជាង ៥០% បានសម្តែងក្តីបារម្ភអំពីហានិភ័យនៃការរឹបអូសឧបករណ៍ថតសំឡេង ឬម៉ាស៊ីនថតវីដេអូ ដែលបង្ហាញពីបញ្ហាប្រឈម ដែលនៅតែបន្តកើតមានចំពោះសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការប្រមូល និងរក្សាទុកព័ត៌មានដោយសុវត្ថិភាព។ ជារួមទិន្នន័យបានបង្ហាញថា សុវត្ថិភាពរបស់អ្នកសារព័ត៌មាននៅតែជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ ដោយវិធានការផ្នែកច្បាប់ និងរដ្ឋបាលបន្តរឹតត្បិតសេរីភាពសារព័ត៌មាន និងការរាយការណ៍ព័ត៌មានឯករាជ្យ (តួលេខទី៣) ។[20]

ជាក់ស្តែងករណីមួយដែលម.ក.ប.រ កត់ត្រាពាក់ព័ន្ធនឹងពលរដ្ឋអ្នកសារព័ត៌មានម្នាក់នៅខេត្តពោធិ៍សាត់ ដែលបានរាយការណ៍អំពីជម្លោះនៃការបែងចែកដីធ្លីនៅខេត្តកំពង់ឆ្នាំងក្បែរតំបន់បឹងទន្លេសាប។ ប្រជាពលរដ្ឋបានអះអាងថាដីរបស់ពួកគាត់ត្រូវបានបែងចែកឱ្យទៅពលរដ្ឋមកពីខេត្តផ្សេងៗ។ បន្ទាប់ពីការផ្សាយការិយាល័យព័ត៌មានស្រុកបានចេញសេចក្តីថ្លែងការណ៍មួយ ដោយអះអាងថា ការរាយការណ៍ព័ត៌មាននោះមិនត្រឹមត្រូវ និងមានភាពលម្អៀង និងមិនបានបញ្ជាក់ឱ្យច្បាស់អំពីខ្លឹមសារដែលមានវិវាទឡើយ។ អ្នកសារព័ត៌មានរូបនោះក៏បានទទួលការព្រមានដោយពាក្យសម្តីពីបុគ្គល ដែលមិនស្គាល់អត្តសញ្ញាណឱ្យបញ្ឈប់ការរាយការណ៍អំពីបញ្ហានេះ។ ករណីនេះបានបង្ហាញពីសម្ពាធ និងហានិភ័យដែលអ្នកសារព័ត៌មានប្រឈមនៅពេលរាយការណ៍ព័ត៌មានអំពីបញ្ហាក្នុងមូលដ្ឋានដែលមានភាពរសើប។

ស្រដៀងគ្នានេះដែរ លទ្ធផលពីកិច្ចពិភាក្សាជាក្រុមអ្នកសារព័ត៌មានបានរាយការណ៍អំពីបទពិសោធន៍នៃការប្រមាថដោយពាក្យសម្តី ដូចជាការឃ្លាំមើល និងការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋាន។ លើសពីនេះ អ្នកផ្តល់បទសម្ភាសន៍ព័ត៌មានគន្លឹះម្នាក់ដែលជាពលរដ្ឋអ្នកសារព័ត៌មានជាស្ត្រីបានរាយការណ៍ថា គាត់បានជួបប្រទះការបៀតបៀនផ្លូវភេទក្នុងអំឡុងពេលចុះបំពេញបេសកកម្មនៅទីតាំងជាក់ស្តែង។ ហើយអ្នកសារព័ត៌មានមួយចំនួនត្រូវបានបុគ្គលមានអំណាចទាមទារឱ្យលុបខ្លឹមសារព័ត៌មានរបស់ពួកគេចេញពីទម្រង់អនឡាញ និងគេហទំព័រព័ត៌មាន។ អ្នកផ្សេងទៀតបានរាយការណ៍ថា ពួកគាត់ត្រូវបានរារាំងមិនឱ្យថតវីដេអូ ឬថតរូបនៅទីសាធារណៈសម្រាប់ការរាយការណ៍ព័ត៌មាននោះទេ និងទទួលបានការគាំទ្រតិចតួច បន្ទាប់ពីបានជួបប្រទះហេតុការណ៍ដែលយាយី។ ករណីការបៀតបៀនផ្លូវភេទមួយក៏ត្រូវបានរាយការណ៍ផងដែរ ហើយបានបង្កើនការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ពលរដ្ឋអ្នកសារព័ត៌មានជាស្ត្រីនៅពេលចុះរាយការណ៍ព័ត៌មាននៅទីតាំង។

[20] អ្នកឆ្លើយតបត្រូវបានសួរថា៖ «នៅឆ្នាំ២០២៥ តើអ្នកបានជួបប្រទះបញ្ហាសុវត្ថិភាពអ្វីខ្លះ ខណៈពេលបំពេញការងាររបស់អ្នក?» ដោយអនុញ្ញាតឱ្យជ្រើសរើសចម្លើយលើសពីមួយ។

## ១.៥. បទពិសោធន៍បញ្ហាសុវត្ថិភាពដែលជួបប្រទះ




ក្នុងចំណោមអ្នកចូលរួមស្ទង់មតិចំនួន ១០៩នាក់ ប្រមាណជា ៣៩% បានរាយការណ៍ថាពួកគាត់បានជួបប្រទះបញ្ហាពាក់ព័ន្ធនឹងសុវត្ថិភាព ខណៈពេលបំពេញការងារនៅទីតាំងជាក់ស្តែង (តួលេខទី៤)។ បញ្ហាប្រឈម ដែលកើតញឹកញាប់បំផុត មានដូចជា ការយាយីដោយពាក្យសម្តី ការឃ្លាំមើលពីអាជ្ញាធរ ឬបុគ្គលមានអំណាច ការគំរាមកំហែងចាប់ខ្លួនដាក់ពន្ធនាគារ ឬការចាត់វិធានការផ្លូវច្បាប់ ការរឹបអូសឧបករណ៍ និងការរំលោភលើឯកជនភាព។

## ១.៦ ទំនាក់ទំនងរវាងអ្នកសារព័ត៌មានជាមួយស្ថាប័នរដ្ឋ និងអាជ្ញាធរមូលដ្ឋានក្នុងពេលចុះយកព័ត៌មាន




មន្ត្រីអនុវត្តច្បាប់ (នគរបាល យោធា និងកងកម្លាំងសន្តិសុខ) ត្រូវបានរាយការណ៍ញឹកញាប់ជាងគេថា ជាអ្នកបង្កការយាយីគំរាមកំហែងដោយមាន៣៥% (២៨នាក់ក្នុងចំណោម ៨០នាក់) រីឯអាជ្ញាធរមូលដ្ឋាន ដូចជា មេភូមិ និង មេឃុំ ត្រូវបានរាយការណ៍ថាជាអ្នកបង្កការយាយីស្ថិតនៅលំដាប់បន្ទាប់មាន២៦% (២១នាក់ក្នុងចំណោម៨០នាក់) ។ លទ្ធផលនេះបង្ហាញក្តីបារម្ភកាន់តែខ្លាំងពាក់ព័ន្ធនឹងការគំរាមកំហែងលើអ្នកសារព័ត៌មានពីសំណាក់អាជ្ញាធរ ឬស្ថាប័នរដ្ឋដែលតាមផ្លូវច្បាប់មានកាតព្វកិច្ចការពារសិទ្ធិ និងសុវត្ថិភាពសាធារណជនជាជាងបង្កហានិភ័យដល់សិទ្ធិ និងសុវត្ថិភាព។

### ករណីសិក្សាទី១៖ អ្នកសារព័ត៌មានសេរីនៅជួរមុខ ប្រឈមហានិភ័យផ្លូវច្បាប់ និងការរឹតត្បិតការទទួលបានព័ត៌មាន

ករណីសិក្សានេះផ្តែកលើកិច្ចពិភាក្សាក្រុមជាមួយអ្នកសារព័ត៌មានសេរីចំនួន៤នាក់។ អ្នកសារព័ត៌មានសេរីនៅកម្ពុជាដែលបំពេញការងារនៅជួរមុខ ប្រឈមនឹងសម្ពាធផ្លូវច្បាប់កាន់តែកើនឡើង ហើយការការពារ

ពីស្ថាប័នពាក់ព័ន្ធនៅមានកម្រិតដែលធ្វើឱ្យពួកគាត់ប្រឈមនឹងហានិភ័យនានាដែលជាញឹកញាប់ត្រូវបានមើលរំលង។ ការស្នើសុំបណ្ណសារព័ត៌មានមានភាពមិនច្បាស់លាស់ និងពិបាកក្នុងការអនុវត្តតាម។ អ្នកសារព័ត៌មានសេរីបានរៀបរាប់ថា លក្ខខណ្ឌមួយចំនួនដូចជាការតម្រូវឱ្យមានឈ្មោះជាអ្នករាយការណ៍ក្នុងអត្ថបទផ្សាយអាចធ្វើឱ្យអ្នកសារព័ត៌មានសេរី និងអ្នកសម្របសម្រួលព័ត៌មានក្នុងស្រុកដែលជាញឹកញាប់មិនមានឈ្មោះជាអ្នករាយការណ៍ផ្លូវការក្នុងអត្ថបទផ្សាយត្រូវបានផាត់ចេញពីលទ្ធភាពទទួលបានបណ្ណសារព័ត៌មាន។ បន្ថែមពីនេះ បណ្ណសារព័ត៌មានបណ្ដោះអាសន្នដែលត្រូវបានប្រើប្រាស់អំឡុងពេលជម្លោះព្រំដែនខ្មែរ–ថៃ ក៏ភ្ជាប់មកជាមួយលក្ខខណ្ឌតម្រូវឱ្យមានការពិនិត្យអត្ថបទមុនពេលផ្សព្វផ្សាយផងដែរ។ អ្នកសារព័ត៌មានបានបង្ហាញក្ដីបារម្ភថា លក្ខខណ្ឌបែបនេះបានរឹតត្បិតឯករាជ្យភាពនៃការនិពន្ធផ្សាយ។

ភាពងាយរងគ្រោះផ្នែកច្បាប់ ក៏ជាបញ្ហាប្រឈមដែលបន្តអូសបន្លាយផងដែរ។ អ្នកសារព័ត៌មានសេរីមួយចំនួនបានរៀបរាប់ពីបទពិសោធន៍របស់ខ្លួនដែលត្រូវបានឃាត់ខ្លួន ឬសាកសួរយូរម៉ោង ក្នុងពេលកំពុងរាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងការកាប់ព្រៃឈើខុសច្បាប់ ឬបទល្មើសបរិស្ថាន។ ការទទួលបានព័ត៌មានផ្លូវការ ក៏ត្រូវបានរឹតត្បិតផងដែរ។ អ្នកសារព័ត៌មានសេរី បានលើកឡើងពីការលំបាកក្នុងការស្នើសុំបទសម្ភាសន៍ពីមន្ត្រីរដ្ឋាភិបាល ដោយជាញឹកញាប់មន្ត្រីណែនាំឱ្យអ្នកសារព័ត៌មានទៅប្រើប្រាស់សេចក្ដីថ្លែងការណ៍ផ្លូវការជាជាងផ្ដល់បទសម្ភាសន៍ផ្ទាល់។ ក្នុងករណីខ្លះទៀត អ្នកសារព័ត៌មានសេរីត្រូវបានរឹតត្បិតក្នុងរូបភាពមិនអនុញ្ញាតឱ្យចូលរួមសន្និសីទសារព័ត៌មានជាដើម ដែលបានរំខានដល់ការទទួលបានព័ត៌មានទាន់ពេល។ ផលប៉ះពាល់ផ្លូវចិត្តពីការរាយការណ៍ស្ថានការណ៍តានតឹងនានា ក៏ជាបញ្ហាសំខាន់មួយនៅក្នុងកិច្ចពិភាក្សាផងដែរ។ អ្នកសារព័ត៌មានសេរីបានរៀបរាប់ថា ពួកគាត់ប្រឈមនឹងការប៉ះទង្គិចផ្លូវចិត្តក្រោយរាយការណ៍អំពីហេតុការណ៍ហិង្សា ការជម្លៀសជនភៀសសឹក ឬការសម្លុតជនរងគ្រោះដោយអំពើហិង្សានៅក្នុងទីតាំងឆបោកតាមអនឡាញជាដើម។

ក្នុងកិច្ចពិភាក្សានេះ អ្នកសារព័ត៌មានសេរីបានអំពាវនាវឱ្យមាននីតិវិធីច្បាស់លាស់ក្នុងការស្នើសុំបណ្ណសារព័ត៌មាន ការពង្រឹងការការពារផ្នែកច្បាប់កាន់តែរឹងមាំ និងការពង្រីកការគាំទ្រផ្នែកសុវត្ថិភាព និងសុខភាពផ្លូវចិត្តដើម្បីធានាថា អ្នកសារព័ត៌មានសេរីអាចបន្តរាយការណ៍ព័ត៌មានដោយឯករាជ្យ។

### ករណីសិក្សាទី២៖ ពលរដ្ឋអ្នកសារព័ត៌មានប្រឈមការបៀតបៀន និងហានិភ័យផ្លូវច្បាប់

លទ្ធផលនៃករណីសិក្សានេះផ្អែកលើកិច្ចពិភាក្សាក្រុមជាមួយពលរដ្ឋអ្នកសារព័ត៌មានចំនួន៥នាក់។ ពលរដ្ឋអ្នកសារព័ត៌មានមួយចំនួននៅកម្ពុជាបានរាយការណ៍ពីការកើនឡើងហានិភ័យក្នុងពេលប្រមូលព័ត៌មានពាក់ព័ន្ធនឹងបញ្ហាសហគមន៍ និងអភិបាលកិច្ចនៅមូលដ្ឋាន។ កិច្ចពិភាក្សាជាមួយពលរដ្ឋអ្នកសារព័ត៌មានបានបង្ហាញពីការបំភិតបំភ័យ ការបៀតបៀន និងការគំរាមកំហែងផ្លូវច្បាប់ពាក់ព័ន្ធនឹងការបំពេញការងារ។ ពលរដ្ឋអ្នកសារព័ត៌មាន បានលើកឡើងថាអាជ្ញាធរបានរារាំងមិនឱ្យថតវីដេអូ ឬប្រមូលព័ត៌មានក្នុងពេលចុះបំពេញ

ការងារ។ ក្នុងករណីខ្លះ អ្នកសារព័ត៌មានបានទទួលរងការប្រើពាក្យសម្តីប្រមាថ ឬការគំរាមកំហែងរូបរាងកាយក្នុងពេលកំពុងប្រមូលព័ត៌មានទៀតផង។

ពលរដ្ឋអ្នកសារព័ត៌មានជាស្រ្តី ក៏បានរាយការណ៍ពីការប្រឈមនឹងការបៀតបៀនផ្លូវភេទក្នុងពេលចុះបំពេញការងារនៅទីតាំងប្រមូលព័ត៌មានផងដែរ។ ទោះបីមានករណីខ្លះត្រូវបានរាយការណ៍ទៅអង្គការសង្គមស៊ីវិល ឬអាជ្ញាធរក៏ដោយការឆ្លើយតបជាញឹកញាប់មានភាពយឺតយ៉ាវ ឬមិនមានប្រសិទ្ធភាព។ ពលរដ្ឋអ្នកសារព័ត៌មានភាគច្រើនមិនមានបណ្ណសារព័ត៌មានដែលទទួលស្គាល់ជាផ្លូវការនោះទេ ដែលនេះបានបង្កការលំបាកក្នុងការធ្វើបទសម្ភាសន៍ ឬចូលទៅយកព័ត៌មាននៅតាមទីតាំងជាក់លាក់មួយចំនួន។ អ្នករាយការណ៍ព័ត៌មានមួយចំនួនបានលើកឡើងថា ការតម្រូវឱ្យបង្ហាញបណ្ណសារព័ត៌មានពីសំណាក់អាជ្ញាធរបានក្លាយជាឧបសគ្គដល់ការរាយការណ៍អំពីបញ្ហានៅក្នុងសហគមន៍។

ក្នុងករណីខ្លះពលរដ្ឋអ្នកសារព័ត៌មានបានរៀបរាប់ថា ពួកគាត់បានទទួលរងការគំរាមចាប់ខ្លួន ឬសម្ពាធឱ្យលុបអត្ថបទព័ត៌មានដែលបានផ្សព្វផ្សាយរួចពាក់ព័ន្ធនឹងប្រធានបទរសើបដូចជា តម្លៃស្រូវធ្លាក់ថ្លៃ អំពើពុករលួយ ឬបញ្ហាបរិស្ថានជាដើម។ ទោះជាយ៉ាងណា ពួកគាត់បានបដិសេធមិនលុបការរាយការណ៍ព័ត៌មាន ទោះបីប្រឈមនឹងហានិភ័យក៏ដោយ។ អ្នកខ្លះទៀត បានលើកឡើងថា ពួកគាត់បានប្រឈមនឹងការឃ្លាំមើល ឬសម្ពាធផ្សេងៗក្រោយការចុះផ្សព្វផ្សាយអត្ថបទព័ត៌មានពាក់ព័ន្ធនឹងបញ្ហាអភិបាលកិច្ច ឬបរិស្ថាន។ ទោះបីប្រឈមនឹងបញ្ហាទាំងនេះក៏ដោយ អ្នកសារព័ត៌មានពលរដ្ឋជាច្រើននៅតែបន្តប្តេជ្ញាចិត្តក្នុងការរាយការណ៍ព័ត៌មានអំពីស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន។ ពួកគាត់បានលើកឡើងពីសារៈសំខាន់នៃវិជ្ជាជីវៈសារព័ត៌មានក្នុងការឆ្លុះបញ្ចាំងអំពីបញ្ហា និងក្តីកង្វល់របស់សហគមន៍ព្រមទាំងអំពាវនាវឱ្យមានយន្តការការពារកាន់តែរឹងមាំ កិច្ចសហការជាមួយអាជ្ញាធរកាន់តែប្រសើរ និងការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីគាំទ្រដល់ការងាររាយការណ៍ព័ត៌មាន។

## III. របកគំហើញទី២៖ ប្រធានបទរសើបនាំឱ្យមានការបារម្ភចំណោមអ្នកសារព័ត៌មាន

តួលេខទី៦៖ ការបារម្ភរបស់អ្នកសារព័ត៌មានតាមប្រធានព័ត៌មាន




«អំពើពុករលួយ» គឺជាប្រធានបទដែលបង្កក្តីបារម្ភខ្លាំងបំផុតក្នុងចំណោមអ្នកសារព័ត៌មាន ដោយមាន ៧៥% (៨២នាក់ក្នុង ចំណោម១០៩នាក់) នៃពួកគាត់បានរាយការណ៍។[21] លំដាប់បន្ទាប់គឺ «ការរុករកធនធានធម្មជាតិដោយខុសច្បាប់ និងការកាប់បំផ្លាញព្រៃឈើ» ត្រូវបានលើកឡើងថាមាន (៧២%, ៧៩នាក់ក្នុងចំណោម១០៩នាក់)។[22] ផ្ទុយទៅវិញ ប្រធានបទដូចជា «ការប្រែប្រួលអាកាសធាតុ» (៤៦%, ៥០នាក់ក្នុងចំណោម១០៩នាក់) និង «ការបៀតបៀន និងការកេងប្រវ័ញ្ចផ្លូវភេទ» (៣៩%,៤២នាក់ក្នុងចំណោម១០៩នាក់) ស្ថិតក្នុងចំណោមប្រធានបទដែលត្រូវបានរាយការណ៍ថាមានក្តីបារម្ភតិចជាងគេ។ លទ្ធផលទាំងនេះឆ្លុះបញ្ចាំងថា ការរាយការណ៍លើប្រធានបទរសើប អាចនាំឱ្យអ្នកសារព័ត៌មានប្រឈមនឹងហានិភ័យខ្ពស់ក្នុងការទទួលបានប្រតិកម្មត្រលប់មកវិញ (តួលេខទី៦)។

លទ្ធផលនេះ ស្របគ្នានឹងបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ដោយអ្នកសារព័ត៌មានដែលធ្វើការលើប្រធានបទរសើបជាញឹកញាប់ប្រឈមនឹងសម្ពាធនៅពេលចុះយកព័ត៌មាន។ អ្នកខ្លះត្រូវបានគំរាមកំហែងដោយអាជ្ញាធរ រីឯខ្លះទៀត ត្រូវបានកោះហៅដោយនគរបាល បន្ទាប់ពីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងប្រធានបទរសើប។ ក្នុងករណីខ្លះអ្នកសារព័ត៌មានត្រូវបានស្នើឱ្យដកមាតិកាព័ត៌មានចេញពីទម្រង់អនឡាញ។

[21] អ្នកសារព័ត៌មានសរុបចំនួន ៧៥% បានរាយការណ៍ថា បារម្ភ និងបារម្ភខ្លាំង ចំពោះការរាយការណ៍ ព័ត៌មានអំពីអំពើពុករលួយ។

[22] អ្នកសារព័ត៌មានសរុបចំនួន ៧២% បានរាយការណ៍ថា បារម្ភ និងបារម្ភខ្លាំង ចំពោះការរាយការណ៍ ព័ត៌មានអំពីការកេងប្រវ័ញ្ចធនធានធម្មជាតិ និងការកាប់បំផ្លាញព្រៃឈើ។

បទពិសោធន៍ទាំងនេះបានបង្កើតបរិយាកាសសម្ពាធ ដែលជះឥទ្ធិពលដល់របៀបអនុវត្តការងាររបស់អ្នកសារព័ត៌មាន។

## IV. របកគំហើញទី៣៖ ការទទួលបានព័ត៌មាន

តួលេខទី៧៖ បញ្ហាប្រឈមក្នុងការទទួលបានព័ត៌មាន និងប្រភពព័ត៌មានសម្រាប់អ្នកសារព័ត៌មានឯករាជ្យ




ទិន្នន័យដែលប្រមូលបានពីការស្ទង់មតិបង្ហាញថា «ការលំបាកក្នុងការស្នើសុំព័ត៌មាន ឬបទសម្ភាសន៍ពីមន្ត្រីរដ្ឋាភិបាល» គឺជាឧបសគ្គចម្បង ដោយមានអ្នកចូលរួមការស្ទង់មតិ ៦៥% (៧១នាក់ក្នុងចំណោម១០៩នាក់) បានរាយការណ៍ថា ជានិច្ចកាល ឬជាប្រចាំប្រឈមបញ្ហានេះ។ លំដាប់បន្ទាប់គឺ មានអ្នកឆ្លើយតប ៤១% (៤៥នាក់ក្នុងចំណោម១០៩នាក់) បានរាយការណ៍ថា ជានិច្ចកាល ឬជាប្រចាំជួបការលំបាកក្នុងការស្នើសុំព័ត៌មាន ឬបទសម្ភាសន៍ពីប្រភពព័ត៌មានពីវិស័យឯកជន (តួលេខទី៧)។ លទ្ធផលទាំងនេះបង្ហាញថា ការទទួលបានព័ត៌មានជាពិសេសពីមន្ត្រីរដ្ឋាភិបាលនៅតែជាបញ្ហាចម្បងសម្រាប់អ្នកសារព័ត៌មាន។ បទសម្ភាសន៍ជាមួយអ្នកជំនាញផ្នែកសារព័ត៌មានមានភាពស្របគ្នាទៅហ្នឹងការរកឃើញទាំងនេះផងដែរ។ អ្នកសារព័ត៌មានជាញឹកញាប់ប្រឈមនឹងឧបសគ្គក្នុងការទាក់ទងជាមួយប្រភពព័ត៌មានផ្លូវការ ជាពិសេសនៅពេលស្នើសុំព័ត៌មាន ឯកសារ ឬបទសម្ភាសន៍ពីស្ថាប័នរដ្ឋាភិបាល។ ក្នុងករណីខ្លះ ទោះបីជាអ្នកសារព័ត៌មានបង្ហាញបណ្ណសារព័ត៌មាន ឬបណ្ណសម្គាល់សមាសភាពចេញពីស្ថាប័ន ក៏ប្រភពព័ត៌មាននៅតែបដិសេធមិនឆ្លើយតប។ ឧបសគ្គទាំងនេះបានរឹតត្បិតការទទួលបានព័ត៌មាន និងអាចធ្វើឱ្យអ្នកសារព័ត៌មានបាក់ទឹកចិត្តក្នុងការរាយការណ៍លើប្រធានបទរសើប ឬបញ្ហាសំខាន់ៗផ្សេងទៀត។

របកគំហើញនេះ ក៏ដូចគ្នាជាមួយរបាយការណ៍របស់ ម.ក.ប.រ ផងដែរ។ ជាក់ស្តែង ក្នុងករណីមួយអ្នកសារព័ត៌មានអនឡាញមកពី AK News ដែលកំពុងរាយការណ៍អំពីការតវ៉ាពាក់ព័ន្ធនឹងវិវាទដីធ្លីនៅជិតផ្លូវជាតិ

លេខ៦A បានទទួលរងអាកប្បកិរិយាគំរាមកំហែងក្នុងពេលព្យាយាមសម្ភាសន៍អភិបាលរងខេត្តកណ្ដាល។ វីដេអូមួយដែលត្រូវបានចែករំលែកនៅលើបណ្ដាញសង្គមហ្វេសប៊ុកបង្ហាញថា អភិបាលរងបានរុញអ្នកសារព័ត៌មាន និងប្រើសម្ដីគំរាមកំហែងនៅពេលអ្នកសារព័ត៌មានរូបនោះកំពុងស្នើសុំការបកស្រាយជាផ្លូវការ។[23]

## ករណីសិក្សាទី៣៖ ស្ថាប័នសារព័ត៏មានប្រឈមការគំរាមកំហែង និងការមិនឆ្លើយតបពីអ្នកនាំពាក្យ

អ្នកសារព័ត៌មានវិជ្ជាជីវៈនៅកម្ពុជា កំពុងប្រឈមនឹងសម្ពាធកាន់តែកើនឡើង រួមមានការជ្រៀតជ្រែកលើការងារនិពន្ធផ្សាយក្រោយការផ្សព្វផ្សាយ ការរឹតត្បិតការទទួលបានព័ត៌មានផ្លូវការ និងការមិនឆ្លើយតបពីអ្នកនាំពាក្យរដ្ឋាភិបាល។ ក្នុងកិច្ចពិភាក្សាក្រុមអ្នកសារព័ត៌មានបានលើកឡើងម្ដងហើយម្ដងទៀត ពីក្ដីបារម្ភពាក់ព័ន្ធនឹងការកើនឡើងនៃសំណើពីអាជ្ញាធរ ឱ្យដកអត្ថបទព័ត៌មានក្រោយពេលផ្សព្វផ្សាយរួចហើយ។

អ្នកសារព័ត៌មានបានលើកឡើងថា មានករណីជាច្រើនដែលតំណាងរដ្ឋាភិបាលបានទាក់ទងទៅស្ថាប័នសារព័ត៌មានភ្លាមៗបន្ទាប់ពីអត្ថបទព័ត៌មានត្រូវបានផ្សព្វផ្សាយដើម្បីទាមទារឱ្យដកព័ត៌មានពាក់ព័ន្ធនឹងប្រធានបទរសើប។ ក្នុងឆ្នាំ២០២៥ អត្ថបទព័ត៌មានមួយចំនួនត្រូវបានដកចេញ បន្ទាប់ពីមានសំណើដោយផ្ទាល់ពីអាជ្ញាធរ។ អ្នកសារព័ត៌មានបានពន្យល់ថា អ្នកនាំពាក្យជាញឹកញាប់មិនបានឆ្លើយតបនឹងសំណើសុំការបកស្រាយ ឬសម្ភាសន៍អំឡុងពេលសរសេរ ឬរាយការណ៍អត្ថបទព័ត៌មាននោះទេ ប៉ុន្តែក្រោយពេលផ្សព្វផ្សាយរួចបែរជាទាមទារឱ្យដកអត្ថបទព័ត៌មានទាំងស្រុង។ សំណើទាំងនេះកម្រត្រូវបានលើកឡើងក្នុងន័យកែតម្រូវព័ត៌មាន ឬបញ្ជាក់ការពិតណាស់។ ផ្ទុយទៅវិញ អ្នកសារព័ត៌មានបានលើកឡើងថា ជាញឹកញាប់ពួកគាត់ត្រូវបានស្នើឱ្យដក ឬលុបអត្ថបទព័ត៌មានទាំងស្រុង។ ក្នុងករណីខ្លះអ្នកសារព័ត៌មានត្រូវបានព្រមានថាការមិនអនុវត្តតាមអាចនាំឱ្យមានចំណាត់ការផ្លូវច្បាប់ដោយអាជ្ញាធរជាញឹកញាប់អះអាងថា ការរាយការណ៍ព័ត៌មានបែបនេះអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់រដ្ឋាភិបាល ឬប្រទេសកម្ពុជា។

ការទទួលបានប្រភពព័ត៌មានផ្លូវការក៏ត្រូវបានលើកឡើងថា កាន់តែមានភាពរឹតត្បិតផងដែរ។ អ្នកសារព័ត៌មានជាច្រើនបានរាយការណ៍ថា អ្នកនាំពាក្យមិនឆ្លើយតបនឹងសំណើសុំបទសម្ភាសន៍ ឬតែងតែលើកឡើងថាមិនមានពេលផ្ដល់ការបកស្រាយផ្ទាល់មុខដល់គ្រប់ស្ថាប័ន។ ហេតុនេះ អ្នកសារព័ត៌មានពេលខ្លះត្រូវបានណែនាំឱ្យដកស្រង់ពីសេចក្ដីថ្លែងការណ៍ផ្លូវការ ឬសារជាសំឡេងដែលបានចែកចាយតាមបណ្ដាញទំនាក់ទំនងតេឡេក្រាមរបស់មន្ត្រីរដ្ឋាភិបាល។ អ្នកសារព័ត៌មានមួយចំនួនក៏បានរាយការណ៍ថាត្រូវបានអ្នកនាំពាក្យ ឬអាជ្ញាធរបិទការទំនាក់ទំនង (block) តាមបណ្ដាញតេឡេក្រាមថែមទៀតផង បន្ទាប់ពីព្យាយាមស្នើសុំការបញ្ជាក់បន្ថែម ឬសួរសំណួរជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការរិះគន់នានា។ អ្នកចូលរួមក្នុងកិច្ចពិភាក្សាក្រុមក៏បានបង្ហាញក្ដីបារម្ភអំពីប្រកាសស្ដីពីលក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន ចេញដោយក្រសួងព័ត៌មានដោយចាត់ទុកថាមានភាពតឹងរ៉ឹងខ្លាំងពេក និងមិនស្របទាំងស្រុងទៅនឹងស្ថានភាពជាក់ស្ដែងនៃបរិយាកាសសារព័ត៌មាននាពេលបច្ចុប្បន្ន។ ការគួបផ្សំគ្នារវាងសម្ពាធក្រោយការផ្សព្វផ្សាយ និងការបង្កើតបទប្បញ្ញត្តិថ្មីៗទាំងនេះ បានធ្វើឱ្យអ្នកសារព័ត៌មានមានការប្រុងប្រយ័ត្នកាន់តែខ្លាំងក្នុងការរាយការណ៍ព័ត៌មាន។

[23] «របាយការណ៍ស្ដីពីការតាមដានឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មានប្រចាំត្រីមាស», ម.ក.ប.វ, ខែធ្នូ ឆ្នាំ២០២៥, https://ccimcambodia.org/wp-content/uploads/2026/01/Eng-Incidents-Report-Against-Journalists-in-Cambodia.pdf.

អ្នកសារព័ត៌មានបានស្នើថា ការពង្រឹងការគាំទ្រពីស្ថាប័នសារព័ត៌មាន នៅពេលប្រឈមនឹងសំណើឱ្យដកអត្ថបទព័ត៌មាន ការពង្រឹងជំនួយផ្នែកច្បាប់ពីអង្គការសង្គមស៊ីវិល និងការបង្កើនការសហការឆ្លើយតបពីអ្នកនាំពាក្យរដ្ឋាភិបាលនឹងជួយជានាឱ្យទំនាក់ទំនងរវាងអាជ្ញាធរ និងប្រព័ន្ធផ្សព្វផ្សាយមានតម្លាភាព និងប្រកបដោយវិជ្ជាជីវៈ។

## V. របកគំហើញទី៤៖ ភាពតានតឹងផ្លូវចិត្តពាក់ព័ន្ធនឹងការងារ និងសុខភាពផ្លូវចិត្តរបស់អ្នកសារព័ត៌មាន

ការសិក្សានេះ បានពិនិត្យអំពីភាពតានតឹងផ្លូវចិត្តពាក់ព័ន្ធនឹងការងាររបស់អ្នកសារព័ត៌មាន។ លទ្ធផលបង្ហាញថា អ្នកសារព័ត៌មានដែលបានចូលរួមស្ទង់មតិភាគច្រើនកំពុងប្រឈមនឹងសម្ពាធផ្លូវចិត្តយ៉ាងខ្លាំង។ អ្នកសារព័ត៌មានភាគច្រើនបានបង្ហាញក្តីបារម្ភអំពីបញ្ហាហិរញ្ញវត្ថុ និងសុវត្ថិភាពផ្ទាល់ខ្លួន។ ពាក់កណ្តាលនៃអ្នកចូលរួមស្ទង់មតិបានរាយការណ៍ពីសម្ពាធដែលកើតចេញពីបុគ្គលមានអំណាច និងភាពតានតឹងផ្លូវចិត្តពាក់ព័ន្ធនឹងការរាយការណ៍លើប្រធានបទរសើប។

ដើម្បីកាត់បន្ថយភាពតានតឹងនេះ អ្នកសារព័ត៌មានច្រើនតែពឹងផ្អែកលើការគាំទ្រក្រៅផ្លូវការ។ ភាគច្រើននៃពួកគាត់ស្វែងរកជំនួយពីមិត្តភក្តិ និងសហការី ឬជាទូទៅប្រើប្រាស់យុទ្ធសាស្ត្រផ្ទាល់ខ្លួនក្នុងការបន្ធូរបន្ថយផលប៉ះពាល់។ ទោះជាយ៉ាងណាការទទួលបានការគាំទ្របែបផ្លូវការនៅមានកម្រិតនៅឡើយ។ អ្នកសារព័ត៌មានតិចជាង ៣០% បានរាយការណ៍ថា បានប្រើប្រាស់សេវាប្រឹក្សា ឬព្យាបាល កម្មវិធីសុខភាពពីអង្គការវិជ្ជាជីវៈ ឬការគាំទ្រសុខភាពផ្លូវចិត្តនៅកន្លែងការងារ។ គួរឱ្យកត់សម្គាល់ថា អ្នកសារព័ត៌មាន ១៨% បានលើកឡើងថា ពួកគាត់មិនមានប្រព័ន្ធគាំទ្រណាមួយឡើយ។

បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ក៏បានបង្ហាញបន្ថែមអំពីសម្ពាធទាំងនេះផងដែរ។ អ្នកសារព័ត៌មានជាញឹកញាប់ប្រឈមនឹងភាពហត់នឿយអារម្មណ៍ដោយសារសម្ពាធការងារខ្ពស់ និងកង្វះបុគ្គលិកនៅក្នុងស្ថាប័ន។ ការប្រឈមនឹងការស្តីបន្ទោស ការប្រមាថ និងការគំរាមកំហែង ក៏បានរួមចំណែកបង្កឱ្យមានភាពតានតឹងផ្លូវចិត្ត និងបញ្ហាសុខភាពផ្លូវចិត្តឥតឈប់ឈរផងដែរ។

## VI. របកគំហើញទី៥៖ អ្នកសារព័ត៌មានធ្លាប់រងការបៀតបៀនផ្លូវភេទក្នុងពេលបំពេញការងាររបស់ខ្លួន ក្នុងនោះមាន ៣៥% ប៉ុណ្ណោះនៃពួកគេបានរាយការណ៍ថាស្ថាប័នសារព័ត៌មានរបស់ខ្លួនមានយន្តការគាំទ្រ



ការសិក្សានេះ ក៏បានពិនិត្យអំពីករណីបៀតបៀនផ្លូវភេទដែលប៉ះពាល់ដល់អ្នកសារព័ត៌មានទាំងនៅកន្លែងការងារ និងនៅពេលចុះយកព័ត៌មាន។ ក្នុងចំណោមអ្នកសារព័ត៌មាន ១០៩នាក់ដែលបានចូលរួមស្ទង់មតិ មានការបៀតបៀនផ្លូវភេទចំនួន០៩ករណីត្រូវបាន

រាយការណ៍។ ក្នុងនោះមានអ្នកសារព័ត៌មានស្ត្រី០៧នាក់ និងបុរស០២នាក់។ លទ្ធផលបង្ហាញថា អ្នកសារព័ត៌មានស្ត្រីងាយប្រឈមនឹងការបៀតបៀនផ្លូវភេទច្រើនជាងទាំងនៅកន្លែងការងារ និងទីតាំងយកព័ត៌មាន។

ក្នុងចំណោមករណីទាំង៩ មាន ៦ ករណីត្រូវបានរាយការណ៍ជាផ្លូវការទៅកាន់អ្នកគ្រប់គ្រង ឬផ្នែកធនធានមនុស្ស រីឯ ៣ ករណីទៀតមិនបានរាយការណ៍ឡើយ។ ជនបង្កក្នុងករណីទាំងនេះ រួមមានប្រភពព័ត៌មាន សហការី អ្នកសារព័ត៌មានមកពីស្ថាប័នផ្សេង និងសមាជិកសហគមន៍មូលដ្ឋាន។

បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះបានបង្ហាញថា ការរើសអើងនៅកន្លែងការងារ និងការបៀតបៀនផ្លូវភេទនៅតែជាបញ្ហាប្រឈមដែលបន្តកើតមានក្នុងវិស័យសារព័ត៌មានជាពិសេសចំពោះស្ត្រី។ មានតែអ្នកសារព័ត៌មាន ៣៨ នាក់ក្នុងចំណោម ១០៩ នាក់ (៣៥%) ប៉ុណ្ណោះដែលបានរាយការណ៍ថាស្ថាប័នសារព័ត៌មានរបស់ខ្លួនមានយន្តការសម្រាប់ដោះស្រាយបញ្ហាការគំរាមកំហែង និងការបៀតបៀន។

ដើម្បីកសាងបរិយាកាសការងារប្រកបដោយបរិយាកាស និងសុវត្ថិភាព ស្ថាប័នសារព័ត៌មានត្រូវបានលើកទឹកចិត្តឱ្យបង្កើត និងអនុវត្តឱ្យបានទូលំទូលាយនូវគោលនយោបាយប្រឆាំងការបៀតបៀន បង្កើតប្រព័ន្ធរាយការណ៍ដែលមានភាពងាយស្រួល និងរក្សាការសម្ងាត់ ព្រមទាំងធានាថាបុគ្គលិកទាំងអស់ទទួលបានការបណ្តុះបណ្តាលជាប្រចាំអំពីសិទ្ធិ និងស្តង់ដារក្រមសីលធម៌វិជ្ជាជីវៈនៅកន្លែងការងារ។ ថ្នាក់ដឹកនាំក៏ត្រូវបង្ហាញការប្តេជ្ញាចិត្តឱ្យបានច្បាស់លាស់ និងជាប់លាប់ក្នុងការជំរុញវប្បធម៌ការងារដែលគោរពឆ្លើយតបនឹងយេនឌ័រ និងគ្មានការបៀតបៀនគ្រប់ទម្រង់។

## VII. របកគំហើញទី៦៖ ការឆ្លើយតបយេនឌ័រ និងសមភាពនៅក្នុងស្ថាប័នសារព័ត៌មាន

ក្រៅពីបញ្ហាប្រឈមទូទៅដូចជាការរឹតត្បិត ការបៀតបៀន និងអំពើហិង្សា អ្នកសារព័ត៌មានស្ត្រីក៏ប្រឈមនឹងហានិភ័យជាក់លាក់ពាក់ព័ន្ធនឹងយេនឌ័រ ដែលជះឥទ្ធិពលដល់ការបំពេញវិជ្ជាជីវៈផងដែរ។[24] គិតត្រឹមខែតុលា ឆ្នាំ២០២៥ យោងតាមទិន្នន័យផ្លូវការរបស់រដ្ឋាភិបាល ភាគរយអ្នកសារព័ត៌មានស្ត្រីបានកើនដល់ ១៣% នៃអ្នកសារព័ត៌មានសរុប ចំនួន ៨,៧៣២នាក់នៅទូទាំងប្រទេស។ នេះបង្ហាញពីការកើនឡើងនៃការចូលរួមរបស់ស្ត្រីក្នុងវិស័យសារព័ត៌មានជារឿយៗ ដោយកើនពី ៨.៧% ក្នុងឆ្នាំ២០២៣ និងបន្តកើនឡើង ៦% ក្នុងឆ្នាំ២០២៤។[25]

---

[24] ឡាយ សុភាវតី និងតេង យ៉ាលីវ៉ូហ្សី, «ចំនួនអ្នកសារព័ត៌មានស្ត្រីកម្ពុជាកំពុងកើនឡើង», ខេមបូឌាណេស (Cambodianess), ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២, https://cambodianess.com/article/cambodian-women-journalists-on-the-rise

[25] «របាយការណ៍ស្តីពីស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា», ក្រសួងព័ត៌មាន, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥, https://www.information.gov.kh/articles/.

បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ក៏បានបញ្ជាក់ពីការរកឃើញទាំងនេះផងដែរ។ អ្នកសារព័ត៌មានស្ត្រី ប្រឈមនឹងបញ្ហាដែលប្រទាក់ក្រឡាគ្នាទាំងផ្នែករចនាសម្ព័ន្ធ វិជ្ជាជីវៈ និងយេនឌ័រ។ តំណាងរបស់ស្ត្រីនៅតែមានកម្រិត ជាពិសេសនៅក្នុងតួនាទីរាយការណ៍ព័ត៌មាននៅជួរមុខ។ ស្ត្រីជាច្រើនត្រូវបានកំណត់ឱ្យបំពេញតួនាទីផ្នែកផលិតកម្ម ឬជាពិធីករ ដែលធ្វើឱ្យឱកាសក្នុងការទទួលបានការងារសំខាន់ៗមានកម្រិត។ ទោះបីស្ត្រីជាច្រើន មានឆន្ទៈទទួលយកភារកិច្ចការងារលំបាកក៏ដោយ ឧបសគ្គដូចជាក្តីបារម្ភអំពីសុវត្ថិភាព ការកំណត់តួនាទីការងារ និងការរំពឹងទុកពីគ្រួសារក៏នៅតែបន្តប៉ះពាល់ដល់ការចូលរួមពេញលេញក្នុងវិជ្ជាជីវៈនេះ។ សម្លេងតំណាងស្ត្រីនៅតែមានតិចតួច ទាំងក្នុងនាមជាអ្នកជំនាញផ្តល់បទសម្ភាសន៍ និងក្នុងការសម្រេចចិត្តនានា ហើយការរើសអើងនៅកន្លែងការងារ នៅតែជាឧបសគ្គរារាំងការរីកចម្រើនក្នុងវិជ្ជាជីវៈនេះផងដែរ។ កត្តាទាំងនេះបានបង្កើតបរិយាកាសលំបាកសម្រាប់ស្ត្រីក្នុងការចូលប្រឡូក បន្តអាជីព និងឡើងតំណែងនៅក្នុងវិជ្ជាជីវៈនេះ។



តួលេខទី៨៖ ការឆ្លើយតប និងការអនុវត្តសមភាពយេនឌ័រនៅក្នុងស្ថាប័នព័ត៌មាន

ជាងពាក់កណ្តាលនៃអ្នកសារព័ត៌មានដែលបានចូលរួមស្ទង់មតិ បានរាយការណ៍ថាស្ថាប័នរបស់ខ្លួនបានអនុវត្តគោលការណ៍ និងការអនុវត្តដែលឆ្លើយតបយេនឌ័រ។ ការអនុវត្តទាំងនេះរួមមាន ការរក្សាតុល្យភាពយេនឌ័រក្នុងចំណោមប្រភពសម្ភាសន៍ និងការជំរុញបរិយាកាសការងារដែលមានបរិយាបន្ន និងការគោរពគ្នាទៅវិញទៅមក។

ជាង ៤០%នៃអ្នកចូលរួមស្ទង់មតិ បានបង្ហាញថាស្ថាប័នសារព័ត៌មានមានវិធានការសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មានស្ត្រី និងអ្នកស្រលាញ់ភេទដូចគ្នាធានាភាពជាតំណាងរបស់ស្ត្រីក្នុងតួនាទីដឹកនាំ និងមានបុគ្គលទទួលបន្ទុក ឬគណៈកម្មការទទួលបន្ទុកផ្នែកយេនឌ័រ (តួលេខទី៨)។ បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បង្ហាញថាការអនុវត្តទាំងនេះជាទូទៅមាននៅក្នុងស្ថាប័នដែលមានស្ត្រីជាដឹកនាំ ឬនៅក្នុងស្ថាប័នសារព័ត៌មានដែលទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិល ឬកម្មវិធីផ្តល់ថវិកាដោយម្ចាស់ជំនួយ។ លទ្ធផល

នេះបង្ហាញថា គោលនយោបាយដែលឆ្លើយតបយេនឌ័រជាទូទៅកើតមានឡើងដោយការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំ និងការគាំទ្រពីដៃគូជំនួយខាងក្រៅ។

### ករណីសិក្សាទី៤៖ អ្នកសារព័ត៌មានស្ត្រីប្រឈមការរើសអើង និងឧបសគ្គរចនាសម្ព័ន្ធ

កិច្ចពិភាក្សាក្រុមជាមួយអ្នកសារព័ត៌មានស្ត្រីចំនួន ៣ នាក់បង្ហាញថា អ្នកសារព័ត៌មានស្ត្រីនៅកម្ពុជានៅតែប្រឈមនឹងការរើសអើងដោយប្រយោល និងកើតមានជាបន្តបន្ទាប់ ជាពិសេសការបែងចែកដោយអយុត្តិធម៌ចំពោះប្រធានបទដែលត្រូវរាយការណ៍។ ជាទូទៅអត្ថបទព័ត៌មានដែលមានហានិភ័យខ្ពស់ ឬប្រធានបទរសើបត្រូវបានផ្តល់ទៅឱ្យអ្នកសារព័ត៌មានបុរសក្រោមហេតុផលសុវត្ថិភាព។ ថ្វីបើយន្តការនេះមានបំណងការពារស្ត្រីក៏ដោយ ប៉ុន្តែការអនុវត្តបែបនេះអាចរឹតត្បិតឱកាសរបស់ស្ត្រី និងដាក់ការសង្ស័យលើសមត្ថភាពរបស់អ្នកសារព័ត៌មានស្ត្រី។ ក្រៅពីភាពមិនស្មើគ្នាក្នុងការបែងចែកភារកិច្ចព័ត៌មាន បរិយាកាសការងារប្រចាំថ្ងៃក៏បានបង្កបញ្ហាប្រឈមផងដែរ។ ការនិយាយកំប្លែងអំពីផ្លូវភេទ និងការលេងសើចបែបរើសអើងយេនឌ័រ ទាំងនៅក្នុងស្ថាប័នសារព័ត៌មាន និងពីប្រភពព័ត៌មាននៅតែកើតមានជាប្រចាំ។ អ្នកសារព័ត៌មានមួយចំនួនបានលើកឡើងថា ពួកគាត់មានទំនុកចិត្តក្នុងការលើកយកបញ្ហាទាំងនេះទៅកាន់ថ្នាក់ដឹកនាំដែលទុកចិត្តបាន ឬធ្វើការរាយការណ៍ជាផ្លូវការ។ អ្នកខ្លះទៀតបានស្វែងរកការគាំទ្រក្រៅផ្លូវការដូចជាការពិភាក្សាជាមួយអ្នកសារព័ត៌មានស្ត្រីដែលមានបទពិសោធន៍ ឬជ្រើសរើសដោះស្រាយដោយស្ងៀមស្ងាត់ តាមរយៈការមិនអើពើនឹងអាកប្បកិរិយាមិនសមរម្យ ដើម្បីជៀសវាងអ្នកដទៃចាត់ទុកថាខ្លួនមានប្រតិកម្មហួសហេតុ។ ថ្វីបើបទពិសោធន៍ការងារជួយឱ្យអ្នកសារព័ត៌មានស្ត្រីអភិវឌ្ឍន៍ភាពរឹងមាំក្នុងការទប់ទល់នឹងបញ្ហាទាំងនេះក៏ដោយ អ្នកសារព័ត៌មានស្ត្រីបានលើកឡើងថា បញ្ហាទាំងនេះបានបង្កភាពតានតឹងផ្លូវចិត្តយ៉ាងខ្លាំង ជាពិសេសនៅពេលចាប់ផ្តើមអាជីពនេះដំបូង។ ប្រព័ន្ធគាំទ្រក៏មានភាពខុសគ្នាតាមស្ថាប័នអង្គការផងដែរ។ ស្ថាប័នសារព័ត៌មានដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាលត្រូវបានមើលឃើញថាផ្តល់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងការគាំទ្រដែលឆ្លើយតបយេនឌ័របានល្អប្រសើរជាងស្ថាប័នសារព័ត៌មានពាណិជ្ជកម្ម។

ក្នុងកិច្ចពិភាក្សាក្រុម អ្នកសារព័ត៌មានស្ត្រីបានអំពាវនាវឱ្យស្ថាប័នសារព័ត៌មានយកចិត្តទុកដាក់ចំពោះការឆ្លើយតបយេនឌ័រដោយមានយន្តការដូចជា ការរៀបចំឱ្យមានការចុះយកព័ត៌មានជាដៃគូ ឬជាក្រុម ដើម្បីធានាសុវត្ថិភាពក្នុងការរាយការណ៍ព័ត៌មានបែបរសើប និងស៊ើបអង្កេត ព្រមទាំងការបញ្ចូលការយល់ដឹងអំពីយេនឌ័រទៅក្នុងការផ្សព្វផ្សាយព័ត៌មាន។ ក្រៅពីនេះពួកគាត់ក៏បានលើកឡើងពីតម្រូវការកំណែទម្រង់ជាក់ស្តែងនៅកន្លែងការងារ ដូចជាការអនុញ្ញាតឱ្យមានការឈប់សម្រាកពេលមករដូវ ការផ្តល់ផលិតផលអនាម័យសម្រាប់ស្ត្រីដោយឥតគិតថ្លៃ និងការជំរុញឱ្យថ្នាក់ដឹកនាំមានការយោគយល់កាន់តែច្រើនចំពោះសុខភាពពាក់ព័ន្ធនឹងការមករដូវ។

## VIII. របកគំហើញទី៧៖ យន្តការគាំទ្រសម្រាប់អ្នកសារព័ត៌មាន

តួលេខទី៩៖ ការគាំទ្រនៅកន្លែងការងារ និងលទ្ធភាពទទួលបានធនធាន




ការសិក្សានេះ ក៏បានវាយតម្លៃអំពីការគាំទ្រដែលស្ថាប័នផ្តល់ដល់អ្នកសារព័ត៌មានផងដែរ។ លទ្ធផលបង្ហាញថា អ្នកសារព័ត៌មានជាច្រើនបានរាយការណ៍ពីការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈ និងគោលការណ៍ណែនាំសម្រាប់ការផលិតព័ត៌មាន។[26] ការអនុវត្តវិធានការការពារខ្លួនអំឡុងពេលចុះយកព័ត៌មាន ការបណ្តុះបណ្តាលសន្តិសុខឌីជីថល និងឱកាសអភិវឌ្ឍន៍ជំនាញក៏ត្រូវបានផ្តល់ជូនដើម្បីគាំទ្រដល់អ្នកសារព័ត៌មានផងដែរ។ ទោះជាយ៉ាងណា មានជាងពាក់កណ្តាលនៃអ្នកចូលរួមស្ទង់មតិប៉ុណ្ណោះ (៥៤% ឬ ៥៩នាក់ក្នុងចំណោម១០៩នាក់) បានលើកឡើងថា ស្ថាប័នរបស់ខ្លួនមានគោលនយោបាយធនធានមនុស្ស សម្រាប់ការពារសិទ្ធិបុគ្គលិក និងផ្តល់ជំនួយផ្នែកច្បាប់។ អ្នកសារព័ត៌មានតិចតួចប៉ុណ្ណោះ ដែលបានរាយការណ៍ថាទទួលបានការគាំទ្រពាក់ព័ន្ធនឹងប្រាក់កម្រៃស្មើភាព គោលការណ៍ឆ្លើយតបយេនឌ័រ ឬវិធានការប្រឆាំងការរើសអើង និងការបៀតបៀនផ្លូវភេទ។

ការគាំទ្រសុខភាពផ្លូវចិត្តនៅមានកម្រិតនៅឡើយ។ មានតែ៣៦% (៣៩នាក់ក្នុងចំណោម១០៩នាក់) នៃអ្នកសារព័ត៌មានដែលចូលរួមស្ទង់មតិប៉ុណ្ណោះដែលរាយការណ៍ថាទទួលបានការគាំទ្រផ្នែកនេះ បើទោះបីមនុស្សជាច្រើនកំពុងមានសម្ពាធផ្លូវចិត្ត និងបញ្ហាប្រឈមយ៉ាងខ្លាំងក៏ដោយ (តួលេខទី៩)។

បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះបង្ហាញថា ការគាំទ្រនៅក្នុងស្ថាប័នសារព័ត៌មានផ្តោតលើស្តង់ដារនៃការនិពន្ធផ្សាយ និងសុវត្ថិភាពក្នុងការរាយការណ៍ព័ត៌មាន។ នេះឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់លើសមត្ថភាពវិជ្ជាជីវៈ និងការគ្រប់គ្រងហានិភ័យ ប៉ុន្តែនៅតែមានចន្លោះខ្វះខាតក្នុងផ្នែកដូចជាសេវាគាំទ្រសុខភាពផ្លូវចិត្ត គោលនយោបាយឆ្លើយតបយេនឌ័រ និងការការពារពីការបៀតបៀន។

---

[26] អ្នកឆ្លើយតបត្រូវបានសួរថា៖ «តើកន្លែងការងាររបស់អ្នកផ្តល់ការគាំទ្រអ្វីខ្លះ?» ដោយអនុញ្ញាតឱ្យជ្រើសរើសចម្លើយបានលើសពីមួយ។

គម្លាតនេះបង្ហាញពីតម្រូវការបន្ទាន់ដែលស្ថាប័នសារព័ត៌មានត្រូវពង្រឹងវិធីសាស្ត្រគាំទ្រសុខុមាលភាពអ្នកសារព័ត៌មានឱ្យមានលក្ខណៈទូលំទូលាយ និងផ្តោតលើសុខុមាលភាពរបស់អ្នកសារព័ត៌មាន ស្របគ្នានឹងការផ្តោតលើការងារនិពន្ធផ្សាយ។

## អ្នកសារព័ត៌មានតិចជាងពាក់កណ្តាលទទួលបានការគាំទ្រផ្នែកច្បាប់ សុវត្ថិភាព និងសុខភាពផ្លូវចិត្ត




លទ្ធផលបង្ហាញពីចំណុចខ្វះខាតសំខាន់ៗរបស់អ្នកសារព័ត៌មានក្នុងការយល់ដឹង និងការទទួលបានការគាំទ្រផ្នែកច្បាប់ និងសុខភាពផ្លូវចិត្ត ។ ជារួមមានតែ៤៥% (៤៩នាក់ក្នុងចំណោម ១០៩នាក់) ប៉ុណ្ណោះដែលបានទទួលការគាំទ្រក្នុងទម្រង់ណាមួយ។ ក្នុងចំណោមអ្នកដែលបានទទួលការគាំទ្រ (៧១ការឆ្លើយតប) ភាគច្រើន៥៤% (៣៨ ក្នុងចំណោម៧១) បានរាយការណ៍ថា ទទួលបានជំនួយពីអង្គការសង្គមស៊ីវិល (CSOs) ខណៈ៣៤% (២៤ ក្នុងចំណោម៧១) ទទួលបានការគាំទ្រតាមរយៈកន្លែងការងារ (តួលេខទី១០)។ ទោះបីមានយន្តការគាំទ្រមួយចំនួនក៏ដោយ អ្នកសារព័ត៌មានជាច្រើនបានលើកឡើងថាជំនួយផ្នែកច្បាប់ និងសុខភាពផ្លូវចិត្ត នៅតែមានកម្រិត។

ចន្លោះឆ្នាំ២០២៥ ដល់ខែមីនា ឆ្នាំ២០២៦ អាជ្ញាធរបានដោះស្រាយបណ្តឹងចំនួន៣៧ករណី ដែលពាក់ព័ន្ធនឹងស្ថាប័នសារព័ត៌មាន និង១១ករណីពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ។[27] ក្រសួងព័ត៌មានបានផ្តល់ការគាំទ្រដល់អ្នកសារព័ត៌មានដែលប្រឈមបញ្ហាផ្លូវច្បាប់ រួមមានការប្រឹក្សាផ្នែកច្បាប់ និងក្នុងករណីខ្លះផ្តល់មេធាវីការពារ។ ក្នុងអំឡុងពេលដូចគ្នា ក្រសួងក៏បានគាំទ្រករណីចំនួន៧ ដែលពាក់ព័ន្ធនឹងស្ថាប័នសារព័ត៌មានចំនួន១២ តាមរយៈការសម្របសម្រួលតំណាងផ្នែកច្បាប់នៅតុលាការ។ យោងតាមអ្នកនាំពាក្យក្រសួងព័ត៌មាន លោក **ទេព អស្នារិទ្ធ** កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមក្នុងការការពារសិទ្ធិអ្នកសារព័ត៌មាន ស្របពេលធានាពីគណនេយ្យភាពផងដែរ។

---

[27] ហុង រស្មី, «ក្រសួងការពារនីតិវិធីច្បាប់ក្នុងសំណុំរឿងអ្នកសារព័ត៌មានជាប់ចោទពីបទក្បត់ជាតិ និងប្តេជ្ញាគាំទ្រអ្នកសារព័ត៌មានដែលប្រកាន់ខ្ជាប់ក្រមសីលធម៌», ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០២៦, https://phnompenhpost.com/national/ministry-defends-legal-process-in-journalists-treason-case-pledges-support-for-ethical-reporters/

## IX. របកគំហើញទី៨៖ ការកើនឡើងនៃព័ត៌មានមិនពិត និងព័ត៌មានបំភាន់ដែលបង្កើតឡើងដោយបញ្ញាសិប្បនិម្មិត

លទ្ធផលពីបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ បង្ហាញថាប្រទេសកម្ពុជាបច្ចុប្បន្ននៅមិនទាន់មានក្របខណ្ឌគោលនយោបាយទូលំទូលាយ សម្រាប់ណែនាំការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតក្នុងវិស័យសារព័ត៌មាននៅឡើយទេ។[28]ស្ថាប័នសារព័ត៌មានជាច្រើនក៏ខ្វះសមត្ថភាពបច្ចេកទេសក្នុងការផ្ទៀងផ្ទាត់មាតិកាដែលត្រូវបានបង្កើត ឬកែច្នៃដោយបញ្ញាសិប្បនិម្មិតផងដែរ។ អ្នកផ្តល់ព័ត៌មានគន្លឹះបានលើកឡើងពីហានិភ័យដូចជា ការបង្កើតព័ត៌មានមិនត្រឹមត្រូវដោយបញ្ញាសិប្បនិម្មិត (AI hallucinations) ភាពលម្អៀងនៃអាល់ហ្គោរីធម៍ (algorithmic bias) និងការកើនឡើងនៃតួនាទីទម្រង់ឌីជីថលក្នុងការចែកចាយមាតិកាព័ត៌មាន។ កត្តាទាំងនេះអាចបន្តរឹតត្បិតលទ្ធភាពទទួលបានព័ត៌មានដែលមានភាពចម្រុះ និងគួរឱ្យទុកចិត្ត។

លទ្ធផលនៃការស្ទង់មតិក៏បានបញ្ជាក់ពីក្តីបារម្ភទាំងនេះផងដែរ។ អ្នកសារព័ត៌មានចំនួន៧៤% (៨១នាក់ក្នុងចំណោម១០៩នាក់) បានបង្ហាញពីតម្រូវការសម្រាប់ការបណ្តុះបណ្តាលអំពីការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងគោលការណ៍ណែនាំច្បាស់លាស់សម្រាប់ស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មាន ក្នុងការប្រើប្រាស់បច្ចេកវិទ្យានេះ ដើម្បីគាំទ្រដល់ការងាររបស់ខ្លួន។ ការពង្រឹងចំណេះដឹងអំពីបញ្ញាសិប្បនិម្មិត គឺមានភាពចាំបាច់។ នេះរួមមានជំនាញក្នុងការផ្ទៀងផ្ទាត់មាតិកា ការប្រើប្រាស់ប្រកបដោយក្រមសីលធម៌ និងសុវត្ថិភាពឌីជីថល។ កង្វះសមត្ថភាពក្នុងការផ្ទៀងផ្ទាត់ និងវាយតម្លៃមាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិត អាចបង្កហានិភ័យខ្ពស់ចំពោះការរីករាលដាលនៃព័ត៌មានមិនពិត និងការភាន់ច្រឡំសាធារណៈ។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក **នេត្រ ភក្ត្រា** ក៏បានព្រមានផងដែរថា ព័ត៌មានមិនពិតដែលបង្កើតដោយបញ្ញាសិប្បនិម្មិតអាចបង្កហានិភ័យដល់ស្ថិរភាពសង្គម ជាពិសេសនៅពេលបច្ចេកវិទ្យាកំពុងដំណើរការលឿនជាងបទប្បញ្ញត្តិដែលមានស្រាប់។[29]

---

[28] «សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសិប្បនិម្មិត ២០២៥-២០៣០», ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ខែមិថុនា ឆ្នាំ២០២៥, https://data.opendevelopmentcambodia.net/en/dataset/5524b0b4-bb31-4cad-abf4-a36f8e82073d/resource/a35e29b9-3dbf-4a5d-92a9-4d3558ed3c03/download/nais-v5-en-for-consultation-clean.pdf

[29] «កម្ពុជារាយការណ៍ថា មានព័ត៌មានក្លែងក្លាយជាង ៣,៦០០ ករណី ក្នុងឆ្នាំ២០២៤», ខេមបូឌាដេលី, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥, https://english.cambodiadaily.com/2025/07/22/cambodia-reports-over-3600-cases-of-fake-news-in-2024/

ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ ទាមទារឱ្យមានវិធីសាស្ត្រទូលំទូលាយដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ការអភិវឌ្ឍស្តង់ដារ និងវិធានការការពារដើម្បីគាំទ្រដល់ភាពត្រឹមត្រូវប្រកបដោយក្រមសីលធម៌ និងគណនេយ្យភាពនៃវិជ្ជាជីវៈ។ ជាពិសេសនៅក្នុងបរិបទឆ្នាំ២០២៥ គណកម្មការ ប្រឆាំងព័ត៌មានក្លែងក្លាយនៃក្រសួងព័ត៌មានមានកត់ត្រាព័ត៌មានក្លែងក្លាយចំនួន ១,០៥៣ ករណីដែលក្នុងនោះមាន ៨៥៤ ករណីពាក់ព័ន្ធនឹងជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបង្កើតដោយមនុស្សនិងការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសប្បនិម្មិត។[30]

តួលេខទី១១៖ ក្តីបារម្ភរបស់អ្នកសារព័ត៌មានអំពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ




អ្នកសារព័ត៌មានចំនួន៦៩% (៧៥នាក់ក្នុងចំណោម១០៩នាក់) បានកំណត់ថា ព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិត ឬព័ត៌មានបំភាន់គឺជាបញ្ហាប្រឈមដ៏ធំមួយ។ ក្នុងនោះ ៣៩% (៤២នាក់ក្នុងចំណោម ១០៩នាក់) បានបង្ហាញក្តីបារម្ភអំពីការកើនឡើងនៃការរឹតត្បិតឌីជីថលពីរដ្ឋាភិបាល ក្រោមហេតុផលប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត (តួលេខទី១១)។ អ្នកតស៊ូមតិផ្នែកសេរីភាពសារព័ត៌មានមានទស្សនៈចម្រុះចំពោះវិធីសាស្ត្ររបស់រាជរដ្ឋាភិបាល។[31] ពួកគាត់បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការទប់ស្កាត់ព័ត៌មានមិនពិត ប៉ុន្តែក៏បានអំពាវនាវឱ្យមានការស៊ើបអង្កេតដោយប្រុងប្រយ័ត្ន និងប្រកបដោយវិជ្ជាជីវៈមុនពេលចាត់វិធានការផ្លូវច្បាប់។ យន្តការនេះមានភាពចាំបាច់ដើម្បីជៀសវាងការរឹតត្បិតដល់ការបញ្ចេញមតិរិះគន់ដែលស្របច្បាប់ ឬមានលក្ខណៈស្ថាបនា។

---

[30] ប្រុស អាន, ក្រសួងព័ត៌មានបានកត់ត្រាព័ត៌មានក្លែងក្លាយចំនួន១០៥៣ ករណីនៅឆ្នាំ២០២៥, ទូរទស្សន៍ជាតិកម្ពុជា ខែតុលា ឆ្នាំ២០២៥ , https://tinyurl.com/bydbcf42

[31] យួន ណារីម, «រដ្ឋាភិបាលដាក់ឱ្យដំណើរការយុទ្ធនាការប្រឆាំងព័ត៌មានក្លែងក្លាយ ខណៈក្រុមអ្នករិះគន់បារម្ភពីការរឹតត្បិតសេរីភាពនៃការបញ្ចេញមតិ», ខេមបូចា, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥, https://cambojanews.com/government-launches-to-anti-fake-news-campaign-opponents-fear-suppression-of-freedom-of-expression/

ការកើនឡើងនៃបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិតកំពុងបង្កើតបញ្ហាប្រឈមថ្មីសម្រាប់វិស័យសារព័ត៌មាន។ បញ្ហាទាំងនេះរួមមាន ការសម្របខ្លួននឹងបច្ចេកវិទ្យាថ្មីៗ ការឆ្លើយតបក្តីបារម្ភផ្នែកក្រមសីលធម៌ និងការអភិវឌ្ឍគោលនយោបាយច្បាស់លាស់សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះនៅក្នុងការិយាល័យព័ត៌មាន។ ទន្ទឹមនឹងនេះបច្ចេកវិទ្យាឌីជីថលជាពិសេសបញ្ញាសិប្បនិម្មិតអាចជួយការអភិវឌ្ឍវិស័យសារព័ត៌មាន តាមរយៈការទទួលបានព័ត៌មានដ៏ទូលំទូលាយ និងពង្រឹងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។ នេះរួមមានការផ្ទៀងផ្ទាត់ព័ត៌មាន ការបង្ហាញទិន្នន័យជារូបភាព (data visualization) និងការផលិតមាតិកាសម្រាប់ផ្សព្វផ្សាយលើទម្រង់ឌីជីថលចម្រុះ។ ទោះជាយ៉ាងណា ការសិក្សានេះបានរកឃើញថាអ្នកសារព័ត៌មានជាង ៦០% (៦៧នាក់ក្នុងចំណោម១០៩នាក់) បានរាយការណ៍ថាសមត្ថភាពរបស់ពួកគាត់នៅមានកម្រិតក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត។ ការព្រួយបារម្ភទាំងនេះ ជាប់ពាក់ព័ន្ធនឹងកំណើនប្រើប្រាស់បញ្ញាសប្បនិម្មិត ដែលយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសប្បនិម្មិតគួរត្រូវអនុម័តសម្រាប់ជាប្រយោជន៍ដ៏សំខាន់ដល់អ្នកសារព័ត៌មានរួមបញ្ចូលទាំងអ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានឱ្យមានចំណេះដឹង និងជំនាញដើម្បីប្រើប្រាស់ AI ប្រកបដោយប្រសិទ្ធិភាព និងទំនួលខុសត្រូវ។ នៅក្នុងន័យនេះដែរ ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានតួនាទីចម្បងក្នុងធានាដល់ការបណ្តុះបណ្តាលអន្តរកម្ម AI ដោយរួមបញ្ចូលក្នុងផែនការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបញ្ញាសប្បនិម្មិតជាមួយនឹងពេលវេលាជាក់លាក់ ធនធានគ្រប់គ្រាន់ និងគោលដៅដែលអាចវាស់វែងបាន។ សំខាន់បំផុត កិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលនេះមិនគួរតែរៀបចំសម្រាប់តែអ្នកសារព័ត៌មានដែលរស់នៅរាជធានីនោះទេ។ អ្នកសារព័ត៌មានដែលនៅតាមបណ្តាខេត្ត អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានដែលកំពុងតែប្រឈមនឹងការតភ្ជាប់អ៊ីនធឺណិត និងស្ថាប័នគាំទ្រ គួរតែជាអាទិភាពដោយស្មើភាពនៅក្នុងផែនការនេះ និងនៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិផ្សេងៗទៀត។

អ្នកផ្តល់ព័ត៌មានគន្លឹះបានបង្ហាញថា ការវិវត្តនៃបច្ចេកវិទ្យាយ៉ាងឆាប់រហ័សកំពុងផ្លាស់ប្តូរវិស័យសារព័ត៌មាន។ ទម្រង់ឌីជីថលកំពុងកែប្រែរបៀបដែលទស្សនិកជនទទួលបានព័ត៌មាន។ បច្ចុប្បន្ន អ្នកប្រើប្រាស់ជាច្រើនពឹងផ្អែកលើបច្ចេកវិទ្យាថ្មីៗ រួមទាំងការប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីស្វែងរកព័ត៌មាន។ ទន្ទឹមនឹងនេះក៏មានការកើនឡើងនៃមាតិកាសំឡេងបង្កើតដោយបញ្ញាសិប្បនិម្មិត ដែលកំពុងកែប្រែទម្លាប់ទទួលព័ត៌មានរបស់ទស្សនិកជន។ ការវិវត្តទាំងនេះធ្វើឱ្យមានការផ្លាស់ប្តូរបរិយាកាសប្រកួតប្រជែងរបស់ស្ថាប័នសារព័ត៌មានក្នុងការទាក់ទាញចំណាប់អារម្មណ៍ទស្សនិកជន។ អ្នកផ្តល់ព័ត៌មានគន្លឹះបានលើកឡើងពីក្តីបារម្ភសំខាន់ៗមួយចំនួនរួមមាន តម្រូវការក្នុងការទទួលយកបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត កង្វះគោលការណ៍ណែនាំច្បាស់លាស់អំពីការប្រើប្រាស់ឌីជីថល និងបញ្ញាសិប្បនិម្មិតនៅក្នុងការិយាល័យព័ត៌មាន និងការលំបាកក្នុងការផ្ទៀងផ្ទាត់មាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិត។ ហេតុនេះស្ថាប័នសារព័ត៌មានចាំបាច់ត្រូវសម្របយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីបន្តឆ្លើយតបទៅនឹងតម្រូវការនៃបរិយាកាសព័ត៌មានបច្ចុប្បន្ន។ ខណៈដែលការ

រាយការណ៍ព័ត៌មានប្រកបដោយភាពត្រឹមត្រូវ និងការសរសេរប្រកបដោយគុណភាព នៅតែជាជំនាញស្នូលដ៏ចាំបាច់ក្នុងវិជ្ជាជីវៈនេះ ការិយាល័យព័ត៌មានក៏ត្រូវពង្រឹងសមត្ថភាពក្នុងការភ្ជាប់ទំនាក់ទំនងជាមួយទស្សនិកជន និងកែលម្អការចែកចាយមាតិកាព័ត៌មានតាមប្រព័ន្ធអនឡាញផងដែរ។

## v. របកគំហើញទី៩៖ តម្រូវការកសាងជំនាញសម្រាប់អ្នកសារព័ត៌មាននាពេលអនាគត

តួលេខទី១២៖ តម្រូវការកសាងសមត្ថភាពរបស់អ្នកសារព័ត៌មាននៅកម្ពុជា




ការសិក្សាក៏បានកំណត់អំពីចំណុចខ្វះខាតផ្នែកសមត្ថភាព និងតម្រូវការជំនាញថ្មីៗក្នុងចំណោមអ្នកសារព័ត៌មានរួមទាំងអ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មានផងដែរ។ លទ្ធផលនេះបង្ហាញពីតម្រូវការខ្ពស់សម្រាប់ការកសាងសមត្ថភាព។ អ្នកសារព័ត៌មានភាគច្រើនដែលបានចូលរួមស្ទង់មតិបានបង្ហាញចំណាប់អារម្មណ៍លើការបណ្តុះបណ្តាលអំពីការរាយការណ៍ព័ត៌មានផ្អែកលើទិន្នន័យ និងជំនាញផលិតព័ត៌មានចម្រុះ (multimedia) មានចំនួន៧៨% (៨៥នាក់ក្នុង ចំណោម១០៩នាក់) ហើយតម្រូវការបន្ទាប់គឺជំនាញបញ្ញាសិប្បនិម្មិតចំនួន ៧៤% (៨១នាក់ក្នុងចំណោម១០៩នាក់) ព្រមទាំងចំនួន ៧៣% (៨០នាក់ក្នុងចំណោម ១០៩នាក់) ត្រូវការជំនាញការពារខ្លួន និងសុវត្ថិភាពនៅពេលរាយការណ៍ព័ត៌មានក្នុងបរិយាកាសដែលមានហានិភ័យខ្ពស់ (តួលេខទី១២)។ គួរកត់សម្គាល់ថា អ្នកសារព័ត៌មានពាក់កណ្តាលដែលបានចូលរួមស្ទង់មតិ ក៏បានលើកឡើងពីតម្រូវការសម្រាប់ការកសាងសមត្ថភាពលើសារព័ត៌មានសហគ្រិនភាពផងដែរ។

ការសិក្សានេះក៏បានបង្ហាញពីភាពចាំបាច់កាន់តែកើនឡើងនៃជំនាញក្នុងការភ្ជាប់ទំនាក់ទំនងជាមួយទស្សនិកជន និងយុទ្ធសាស្ត្រមាតិកាព័ត៌មាន ដើម្បីឱ្យអ្នកសារព័ត៌មានអាចបន្តឆ្លើយតបទៅនឹងតម្រូវការនៃបរិយាកាសព័ត៌មានបច្ចុប្បន្ន និងទាញចំណាប់អារម្មណ៍ទស្សនិកជននៅក្នុងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នេះរួមមាន ការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយវិជ្ជាជីវៈក្នុងការផលិតព័ត៌មាន និងការអភិវឌ្ឍគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីគាំទ្រវិជ្ជាជីវៈសារព័ត៌មានប្រកបដោយក្រមសីលធម៌។ លទ្ធផលក៏បានបង្ហាញថា អ្នកសារព័ត៌មានអាចទទួលបានអត្ថប្រយោជន៍ពីការ

អនុវត្តមួយចំនួនដែលត្រូវបានប្រើប្រាស់ដោយអ្នកបង្កើតមាតិកាដែលបច្ចុប្បន្នកំពុងក្លាយជាផ្នែកមួយនៃប្រព័ន្ធអេកូព័ត៌មាននៅកម្ពុជា។[32] ការអនុវត្តទាំងនេះរួមមាន ការរៀបរាប់សាច់រឿងដោយផ្តោតលើតម្រូវការរបស់ទស្សនិកជន ការផលិតមាតិកាឱ្យសមស្របតាមទម្រង់ឌីជីថលនីមួយៗ និងការប្រើប្រាស់ចំណងជើង និងរូបភាពដែលមានភាពទាក់ទាញដែលអាចនៅតែរក្សាបាននូវភាពត្រឹមត្រូវ និងគួរឱ្យទុកចិត្ត។

វិធីសាស្រ្តទាំងនេះអាចជួយឱ្យអ្នកសារព័ត៌មានទាក់ទាញចំណាប់អារម្មណ៍ទស្សនិកជន និងបង្កើតចំណូលតាមរយៈការផ្សាយពាណិជ្ជកម្មដែលជួយគាំទ្រដល់និរន្តរភាពផ្នែកហិរញ្ញវត្ថុ។ ស្ថាប័នសារព័ត៌មានអាចអភិវឌ្ឍន៍គំរូអាជីវកម្មដែលមាននិរន្តរភាពកាន់តែប្រសើរតាមរយៈប្រភពចំណូលចម្រុះ ដូចជាការបង់ថ្លៃដើម្បីទទួលបានព័ត៌មាន ការបរិច្ចាគពីទស្សនិកជន ការឧបត្ថម្ភលើមាតិកា កិច្ចសហការជាមួយម៉ាកផលិតផល និងការរកចំណូលតាមទម្រង់ឌីជីថល ខណៈនៅតែរក្សាស្តង់ដារ និងគោលការណ៍ស្នូលនៃវិជ្ជាជីវៈ។[33]

---

[32] Ben Reininga and Ryan Y. Kellett, 'តើស្ទាដៃអ្វីខ្លះដែលស្ថាប័នសារព័ត៌មានអាចសិក្សាពីអ្នកផលិតមាតិកា', Nieman Reports, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥, https://niemanreports.org/news-influencers-content-creators-social-media-journalism/

[33] Dawn M. Deguzman, 'ការបើកច្រកចំណូល: តើវីដេអូមាតិការអាចរកប្រាក់ចំណូលដល់ស្ថាប័នសារព័ត៌មានបានយ៉ាងដូចម្តេច', AP, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤, https://www.ap.org/insights/unlocking-revenue-streams-how-video-content-drives-monetization-for-news-media-companies/

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះផ្តល់នូវការវាយតម្លៃដ៏ទូលាយ និងផ្អែកលើស្ថានភាពជាក់ស្តែងអំពីស្ថានភាពវិជ្ជាជីវៈសារព័ត៌មាន និងបញ្ហាប្រឈមដែលអ្នកជំនាញសារព័ត៌មានកំពុងប្រឈមក្រោមលក្ខខណ្ឌការងារដែលកាន់តែលំបាក។

តាមរយៈរបកគំហើញសំខាន់ៗទាំង៩ បង្ហាញថា អ្នកសារព័ត៌មាន ជាពិសេសអ្នកសារព័ត៌មានឯករាជ្យកំពុងប្រឈមនឹងសម្ពាធការងារកាន់តែខ្លាំង ខណៈការគាំទ្រពីស្ថាប័ននៅមានកម្រិតលទ្ធភាព ទទួលបានព័ត៌មានកាន់តែរួមតូច និងហានិភ័យផ្នែកច្បាប់ ព្រមទាំងបញ្ហាប្រឈមរូបរាងកាយ និងផ្លូវចិត្តកាន់ តែកើនឡើង។

លទ្ធផលបង្ហាញយ៉ាងច្បាស់ថា បញ្ហាប្រឈមដែលវិស័យសារព័ត៌មានកំពុងជួបប្រទះមិនមែនជាបញ្ហាដាច់ដោយឡែក ឬកើតឡើងដោយចៃដន្យនោះទេ។ ផ្ទុយទៅវិញ បញ្ហាទាំងនេះមានឫសគល់ផ្នែករចនាសម្ព័ន្ធយ៉ាងជ្រាលជ្រៅ។ រាប់ចាប់ពីការប្រើប្រាស់ការបំភិតបំភ័យដោយមន្ត្រីអនុវត្តច្បាប់ និងអាជ្ញាធរមូលដ្ឋានរហូតដល់កង្វះយន្តការការពារនៅកន្លែងធ្វើការដូចជា គោលនយោបាយប្រឆាំងនឹងការបៀតបៀន និងការរើសអើង ព្រមទាំងគម្លាតសមភាពយេនឌ័រនៅក្នុងស្ថាប័នសារព័ត៌មាន។ បញ្ហាទាំងនេះបានឆ្លុះបញ្ចាំងពីភាពខ្វះខាតជាប្រព័ន្ធដែលទាមទារឱ្យមានការឆ្លើយតប និងការសម្របសម្រួលពីទាំងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ ការកើនឡើងយ៉ាងឆាប់រហ័សនៃព័ត៌មានមិនពិត និងព័ត៌មានបំភាន់ដែលបង្កើតដោយបញ្ញាសិប្បនិម្មិតបានបន្ថែមបញ្ហាប្រឈមថ្មី និងបន្ទាន់មួយទៀតបន្ថែមលើបញ្ហាដែលកំពុងប្រឈមដែលមានស្រាប់។ ប្រសិនបើពុំមានការបណ្តុះបណ្តាលគ្រប់គ្រាន់ គោលការណ៍ណែនាំច្បាស់លាស់ និងការវិនិយោគពីស្ថាប័នលើការលើកកម្ពស់ចំណេះដឹង និងសមត្ថភាពពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិតទេ វិស័យសារព័ត៌មានអាចប្រឈមនឹងការដើរមិនទាន់ការវិវត្តបច្ចេកវិទ្យានូវសមត្ថភាពបម្រើសាធារណជនជាមួយព័ត៌មានដែលមានភាពត្រឹមត្រូវ និងគួរឱ្យទុកចិត្ត។ សំខាន់ជាងនេះទៅទៀត ការសិក្សានេះរកឃើញថា យន្តការគាំទ្រដែលមានសម្រាប់អ្នកសារព័ត៌មាននាពេលបច្ចុប្បន្នមិនថាផ្នែកសុខភាពផ្លូវចិត្ត ប្រាក់បៀវត្សស្មើភាព សុវត្ថិភាពការងារ ឬការអភិវឌ្ឍវិជ្ជាជីវៈនៅតែមិនគ្រប់គ្រាន់ និងមិនត្រូវបានផ្តល់ជូនស្មើភាពនៅឡើយ។ ជាពិសេសអ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មាន នៅតែត្រូវបានមើលរំលងទោះបីការចូលរួមរបស់ពួកគេក្នុងវិស័យសារព័ត៌មាននាពេលបច្ចុប្បន្នកំពុងកើនឡើងក៏ដោយ។

ដើម្បីពង្រឹងវិស័យសារព័ត៌មានការបង្កើនការយល់ដឹងតែមួយមុខមិនទាន់គ្រប់គ្រាន់នោះទេ។ ការងារនេះទាមទារឱ្យមានគណនេយ្យភាព ការវិនិយោគជាបន្តបន្ទាប់ និងកំណែទម្រង់គោលនយោបាយប្រកបដោយប្រសិទ្ធភាព។ នេះរួមមានការធ្វើកំណែទម្រង់ក្របខណ្ឌច្បាប់ដោយផ្តល់អាទិភាពដល់ការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មានដែលមានភាពយុត្តិធម៌ និងផ្តល់ការការពារដល់អ្នកសារព័ត៌មាន ជាជាងការប្រើប្រាស់បទប្បញ្ញត្តិព្រហ្មទណ្ឌមកលើអ្នកសារព័ត៌មាន។ ការឆ្លើយតបចំពោះបញ្ហាទាំងនេះ មិនមែនគ្រាន់តែជាការលើកកម្ពស់សុខុមាលភាពវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែជាមូលដ្ឋានសំខាន់សម្រាប់ការកសាងប្រព័ន្ធផ្សព្វផ្សាយសេរី ឯករាជ្យ និងមានភាពរឹងមាំ ដែលអាចបម្រើផលប្រយោជន៍សាធារណៈបានប្រកបដោយប្រសិទ្ធភាព។

## អនុសាសន៍

យោងតាមលទ្ធផលនៃការសិក្សានេះ ម.ក.ប.រ ស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នសារព័ត៌មាន អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មាន ធ្វើការរួមគ្នាដើម្បីកែលម្អបរិយាកាសសារព័ត៌មាននៅកម្ពុជា។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារកិច្ចខិតខំប្រឹងប្រែងរួមពីភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មានផ្លូវការប្រកបដោយតម្លាភាព ដើម្បីធានាថាបញ្ហានានាត្រូវបានដោះស្រាយដោយគោរពសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបញ្ចេញមតិ។ ដូច្នេះ ម.ក.ប.រ សូមផ្តល់អនុសាសន៍ដូចខាងក្រោម៖

**ក. រាជរដ្ឋាភិបាលកម្ពុជា៖**

- ធានាថាករណីពាក់ព័ន្ធនឹងវិជ្ជាជីវៈសារព័ត៌មាន និងសេរីភាពសារព័ត៌មាន ត្រូវបានដោះស្រាយក្រោមច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ជាជាងការប្រើប្រាស់ក្រមព្រហ្មទណ្ឌ ស្របតាមគោលការណ៍ការពារសេរីភាពខាងការបញ្ចេញមតិ។
- ធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីរបបសារព័ត៌មានឱ្យឆ្លើយតបទៅនឹងការវិវត្តបរិយាកាសប្រព័ន្ធផ្សព្វផ្សាយឌីជីថល រួមទាំងការបញ្ចូលបទប្បញ្ញត្តិស្តីពីការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយការទទួលខុសត្រូវក្នុងវិស័យសារព័ត៌មាន ខណៈធានាការការពារសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ និងមានការចូលរួមពិភាក្សាពីគ្រប់ភាគីពាក់ព័ន្ធ។
- ពន្លឿនការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិ និងពិនិត្យឡើងវិញការអនុវត្តបទប្បញ្ញត្តិក្រមព្រហ្មទណ្ឌ ជាពិសេសបទប្បញ្ញត្តិពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ បទញុះញង់ការប្រមាថជាសាធារណៈ សន្តិសុខជាតិ និងបទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ដើម្បីជៀសវាងការប្រើប្រាស់បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌមកលើអ្នកសារព័ត៌មាន។
- ពិនិត្យ និងកែសម្រួលប្រកាសស្តីពីគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន និងលក្ខខណ្ឌសម្រាប់បណ្ណសារព័ត៌មាន (២០២៥–២០២៦) តាមរយៈការពិគ្រោះយោបល់ប្រកបដោយតម្លាភាព និងបរិយាបន្ន ដើម្បីធានាថាមិនបង្កឧបសគ្គ ឬរឹតត្បិតសេរីភាពសារព័ត៌មាន។
- ពង្រឹងតម្លាភាព និងការឆ្លើយតបរបស់ស្ថាប័នសាធារណៈ តាមរយៈការកែលម្អលទ្ធភាពទទួលបានព័ត៌មានផ្លូវការ បទសម្ភាសន៍ និងទិន្នន័យសាធារណៈសម្រាប់អ្នកសារព័ត៌មាន។
- សម្រួលដំណើរការស្នើសុំបណ្ណសារព័ត៌មាន ជាពិសេសសម្រាប់អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មាន។
- ធានាថាការប្រើប្រាស់ឈ្មោះដែនជាតិ ".kh" មានលក្ខណៈបើកចំហ និងមិនត្រូវបានប្រើប្រាស់សម្រាប់ការរឹតត្បិត ឃ្លាំមើល រារាំង ឬការបដិសេធការចុះឈ្មោះវេបសាយដោយមិនត្រឹមត្រូវឡើយ។

### ខ. អង្គភាពប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលៈ

- គាំទ្រការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយការទទួលខុសត្រូវក្នុងវិស័យសារព័ត៌មាន តាមរយៈការលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ការផ្ទៀងផ្ទាត់ព័ត៌មាន ការវិភាគទិន្នន័យ និងការផលិតព័ត៌មាន ព្រមទាំងបង្កើតគោលការណ៍ណែនាំផ្នែកក្រមសីលធម៌ និងគោលនយោបាយក្នុងស្ថាប័នព័ត៌មាន ដើម្បីកាត់បន្ថយហានិភ័យនៃព័ត៌មានមិនពិត ព័ត៌មានបំភាន់ និងមាតិកានាំឱ្យមានការរើសអើង ។
- ជំរុញនិរន្តរភាពរបស់ប្រព័ន្ធផ្សព្វផ្សាយតាមរយៈការអភិវឌ្ឍគំរូអាជីវកម្ម ឬប្រភពចំណូល ដូចជាការបង់ថ្លៃដើម្បីទទួលបានព័ត៌មាន ការបរិច្ចាគពីទស្សនិកជន ការឧបត្ថម្ភលើមាតិកា និងការរកចំណូលតាមទម្រង់ឌីជីថល ព្រមទាំងស្វែងរកយន្តការផ្ដល់ថវិកាសាធារណៈប្រកបដោយតម្លាភាព ដើម្បីពង្រឹងភាពរឹងមាំវិស័យសារព័ត៌មានរយៈពេលវែង។
- ពង្រីកការការពារ ការបណ្ដុះបណ្ដាល ពង្រឹងសុវត្ថិភាព និងសេវាគាំទ្រសុខភាពផ្លូវចិត្តនិងសុខមាលភាពដល់អ្នកសារព័ត៌មានសេរី និងពលរដ្ឋអ្នកសារព័ត៌មាន ព្រមទាំងផ្តល់កម្មវិធីបណ្តុះបណ្តាលលើការរាយការណ៍ស៊ើបអង្កេត បច្ចេកទេសផ្ទៀងផ្ទាត់ព័ត៌មាន សន្តិសុខឌីជីថល និងបច្ចេកវិទ្យាថ្មីៗ។
- លើកម្ពស់សមភាពយេនឌ័រ និងបង្កើនចំនួនតំណាងរបស់ស្ត្រីក្នុងតួនាទីដឹកនាំតាមរយៈការអនុវត្តវិធានការប្រឆាំងការបៀតបៀន ការធានាបរិយាកាសការងារប្រកបដោយបរិយាបន្ន និងការបង្កើតយន្តការគាំទ្រសម្រាប់ដោះស្រាយការបៀតបៀនផ្លូវភេទ។
- ផ្ដល់អាទិភាពដល់ការគាំទ្រសុខភាពផ្លូវចិត្តជាសេវាស្នូល ដោយធានាឱ្យអ្នកសារព័ត៌មានអាចទទួលបានការប្រឹក្សាប្រកបដោយការសម្ងាត់ បណ្ដាញគាំទ្រពីមិត្តរួមអាជីព និងជំនួយហិរញ្ញវត្ថុបន្ទាន់ ដើម្បីដោះស្រាយបញ្ហាតានតឹងផ្លូវចិត្តដែលបណ្ដាលមកពីហានិភ័យសុវត្ថិភាព និងអស្ថិរភាពហិរញ្ញវត្ថុ។
- បង្កើតមូលនិធិជំនួយផ្នែកច្បាប់ និងយន្តការឆ្លើយតបបន្ទាន់សម្រាប់អ្នកសារព័ត៌មានដែលប្រឈមនឹងការគំរាមកំហែង ឬការឃាត់ខ្លួន។ ចាត់វិធានការដើម្បីទប់ស្កាត់ការគំរាមកំហែងអ្នកសារព័ត៌មានដោយមន្ត្រីអនុវត្តច្បាប់និងអាជ្ញាធរមូលដ្ឋានព្រមទាំងធានាឱ្យមានការស៊ើបអង្កេត និងដាក់ទោសជនប្រព្រឹត្ត។

### គ. អ្នកសារព័ត៌មានៈ

- ចូលរួមយ៉ាងសកម្មក្នុងឱកាសបណ្តុះបណ្តាលលើប្រធានបទសន្តិសុខឌីជីថល ចំណេះដឹងអំពីបញ្ញាសិប្បនិម្មិត ការរាយការណ៍ព័ត៌មានស៊ើបអង្កេត និងបច្ចេកទេសផ្ទៀងផ្ទាត់ព័ត៌មាន ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងភាពរឹងមាំក្នុងការបំពេញការងារ។
- មានភាពសកម្មក្នុងការចូលរួមដំណើរការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់ច្បាប់ស្តីពីរបបសារព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន និងការអភិវឌ្ឍគោលនយោបាយស្តីពីបញ្ញាសិប្បនិម្មិតដើម្បីធានាថាទស្សនៈ និងតម្រូវការរបស់អ្នកសារព័ត៌មានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការសម្រេចចិត្តផ្នែកគោលនយោបាយ។

- រាយការណ៍ករណីបៀតបៀន ការបំភិតបំភ័យ និងការគំរាមកំហែងផ្នែកច្បាប់ តាមរយៈយន្តការជំនួយផ្នែកច្បាប់ ព្រមទាំងកត់ត្រា និងប្រមូលឯកសារពាក់ព័ន្ធនឹងករណីទាំងនោះ ដើម្បីរួមចំណែកដល់ការតស៊ូមតិផ្នែកលើភស្តុតាង សម្រាប់ការលើកកម្ពស់សេរីភាពសារព័ត៌មាន៕

# របាយការណ៍ស្ដីពី
# បញ្ហាប្រឈម
# នៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
# ឆ្នាំ២០២៥

ccimcambodia.org

គ្រប់គ្នាទទួលបានព័ត៌មានគ្រប់គ្នាទទួលបានភាពអង់អាច

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCiM

cambodian center for independent media